ADB

Asian Development Bank

# ការពន្យល់អំពីអតិផរណានៅក្នុងប្រទេសកម្ពុជា

លើកយកមកបង្ហាញនៅក្នុងវេទិកាសេដ្ឋកិច្ចកម្ពុជាលើកទីបី

ភ្នំពេញ

៥ កុម្ភៈ ២០០៩

**ដោយលោក អេឌីម៉ុន ជីនធីង** (Edimon Ginting) **និងលោក ខេលី បឺត** (Kelly Bird)

## សេចក្ដីសង្ខេប

អត្ថបទសិក្សានេះ បង្ហាញនូវការវិភាគបែបគណិតសាស្ត្រដោយផ្អែកលើទិន្នន័យតួលេខអំពីមូលហេតុនៃអតិផរណា។ ដោយសារថាសេដ្ឋកិច្ចមានដុល្លារូបនីយកម្មខ្លាំង ហើយប្រទេសកម្ពុជាមានច្រកព្រំដែនបើកទូលាយរួមជាមួយប្រទេសវៀតណាម និងប្រទេសថៃនោះ ការប្រែប្រួលតម្លៃទំនិញនៅក្នុងប្រទេសកម្ពុជា ត្រូវបានគេរំពឹងទុកថា នឹងទទួលរងនូវឥទ្ធិពលយ៉ាងធ្ងន់ធ្ងរពីកត្តាផ្សេងៗជាមួយប្រទេសជាដៃគូពាណិជ្ជកម្មដ៏សំខាន់ទាំងពីររបស់ខ្លួន។ ការសិក្សាបានរកឃើញថា អតិផរណានៃតម្លៃម្ហូបអាហារជាអន្តរជាតិត្រូវបាននាំឆ្លងចូលមកប្រទេសកម្ពុជាតាមរយៈដៃគូពាណិជ្ជកម្មដ៏សំខាន់របស់ខ្លួន។ កំណើនរូបិយវត្ថុសរុបទាំងមូល ក៏ដើរតួនាទីសំខាន់ផងដែរនៅក្នុងបរិការណ៏ដែលសេដ្ឋកិច្ចមានកំណើនខ្ពស់ជ្រុលពេលបែបនេះ។ ការសិក្សា បានរកឃើញទៀតថា កំណើនសាច់ប្រាក់បានធ្វើឱ្យមានវិបាកដល់អតិផរណានៃទំនិញដែលមិនសម្រាប់ធ្វើពាណិជ្ជកម្ម ដូចបានបង្ហាញតាមរយៈការកើនឡើងនៃអត្រាអតិផរណាគោល។ ការសិក្សានេះ បានធ្វើការសន្និដ្ឋានថា វិធានការសារពើពន្ធ និងរូបិយវត្ថុ ពិតជាមានភាពចាំបាច់ណាស់ដើម្បីគ្រប់គ្រងអតិផរណា។ ហើយការសិក្សានេះ ក៏មានការផ្ដល់ជាយោបល់មួយចំនួនដើម្បីពង្រឹងគោលនយោបាយហិរញ្ញវត្ថុនៅក្នុងរយៈពេលវែង និងប្រកបដោយនិរន្តរភាពដើម្បីកាត់បន្ថយផលប៉ះពាល់នៃការឡើងតម្លៃទំនិញទៅលើគ្រួសារក្រីក្រ និងគ្រួសារដែលងាយទទួលរងគ្រោះ ។

# I. សេចក្តីផ្តើម

១. អាជ្ញាធរកម្ពុជា បានធ្វើសំណើសុំនាយកដ្ឋានតំបន់អាស៊ីអាគ្នេយ៍នៃធនាគារអភិវឌ្ឍន៍អាស៊ី ឱ្យធ្វើការវាយតម្លៃទៅលើដំណើរអតិផរណានៅក្នុងប្រទេសកម្ពុជា ។ សំណើនេះ ត្រូវបានធ្វើឡើងដោយសារមានការកើនឡើងនូវតម្លៃទំនិញជាសាកលដែលមិនបានព្យាករណ៍ទុក និងការរាលដាលដ៏ឆាប់រហ័សនៃការកើនឡើងតម្លៃទំនិញជាសាកលនេះដល់អតិផរណាក្នុងស្រុក ។ ការកើនឡើងអតិផរណាក្នុងស្រុក ក៏មានការកើតឡើងផងដែរ នៅពេលដែលគេសង្កេតឃើញថា កំណើនសេដ្ឋកិច្ចកំពុងតែលឿនជ្រុលពេក និងនៅពេលដែលរូបិយវត្ថុសរុប និងកម្ចីក្នុងស្រុក មានការកើនឡើងនៅក្នុងអត្រាកំណើន ដែលមិនធ្លាប់មានពីមុនមក ។ អាជ្ញាធរមានការព្រួយបារម្ភថា ការកើនឡើងនៃបរិមាណរូបិយវត្ថុសរុបនេះ ក៏ធ្វើឱ្យអតិផរណាក្នុងស្រុកមានសភាពកាន់តែធ្ងន់ធ្ងរឡើងផងដែរ ដូច្នេះហើយទើបតម្រូវឱ្យមានការកំណត់នូវគោលនយោបាយសារពើពន្ធ និងរូបិយវត្ថុរួមបញ្ចូលគ្នាសមស្របដើម្បីគ្រប់គ្រងអតិផរណា ។

២. ការសិក្សានេះ ធ្វើការវាយតម្លៃទៅលើដំណើរអតិផរណានៅក្នុងប្រទេសកម្ពុជាតាមរយៈការធ្វើវិភាគបែបគណិតសាស្ត្រផ្អែកលើទិន្នន័យតួលេខអំពីមូលហេតុនៃអតិផរណា ។[១] ហើយការសិក្សានេះ ក៏បានជាប្រយោជន៍បីយ៉ាងដល់ការពិភាក្សាស្តីពីអតិផរណានៅក្នុងប្រទេសកម្ពុជា ។ ចំណុចទីមួយ ការសិក្សាបានបង្កើតឡើងនូវរង្វាស់ចំនួនពីរសម្រាប់វាស់វែងកម្រិតអតិផរណាគោល (មិនរាប់បញ្ចូលម្ហូបអាហារមិនទាន់កែច្នៃ ថាមពល និងការដឹកជញ្ជូននៅក្នុងតារាងសន្ទស្សន៍តម្លៃ) ដែលអាចឱ្យអាជ្ញាធរកម្ពុជាធ្វើការវាយតម្លៃថា តើផលប៉ះពាល់ពីអតិផរណានៅ *"ក្នុងជុំទីពីរ"* ដែលមានទៅលើសេដ្ឋកិច្ចជាទូទៅនេះ ពិតជាបណ្តាលមកពីកំណើនគំហុកនៃថ្លៃរបស់ទំនិញនាពេលថ្មីៗនេះដែរឬទេ ។ ការសិក្សានេះ ក៏បានផ្តល់ឱ្យអាជ្ញាធរនូវឧបករណ៍មួយដើម្បីធ្វើការវាយតម្លៃផលប៉ះពាល់ *"ក្នុងជុំទីពីរ"* ពីការប្រែប្រួលណាមួយមកលើសេដ្ឋកិច្ចនាអនាគត ។ របៀបគណនាអត្រាគោល មាននៅក្នុងឧបសម្ព័ន្ធ ១ ។ ចំណុចទីពីរ ការសិក្សា នេះក៏បានបង្ហាញអំពីការព្យាករណ៍គណិតសាស្ត្រផ្អែកលើទិន្នន័យតួលេខទៅលើមូលហេតុនៃអតិផរណាផងដែរ ដែលអាចឱ្យយើងធ្វើការញែកឱ្យដាច់ពីគ្នានូវសារៈសំខាន់នៃឥទ្ធិពលពីអន្តរជាតិ និងឥទ្ធិពលពីក្នុងស្រុកមកលើអតិផរណាក្នុងស្រុក ។ លទ្ធផលស្ថិតិ និងម៉ូដែល ក៏បានផ្តល់ឱ្យអាជ្ញាធរនូវឧបករណ៍ដើម្បីធ្វើការព្យាករណ៍អតិផរណាក្នុងរយៈពេលខ្លីផងដែរ ។ ចំណុចទីបី តាមរយៈការធ្វើអត្តសញ្ញាណ និងការកំណត់ចំនួនមូលហេតុនៃអតិផរណានិងការរីករាលដាលរបស់វា អាជ្ញាធរអាចកំណត់នូវវិធានឧបករណ៍រួមបញ្ចូលគ្នាសមស្រប (ទាំងខាងសារពើពន្ធ និងរូបិយវត្ថុ) ដើម្បីគ្រប់គ្រងអតិផរណា ។

៣. អតិផរណា នៅក្នុងប្រទេសកម្ពុជាមានការកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីខែកញ្ញា ឆ្នាំ ២០០៧ មក ។ ចាប់ពីមធ្យមភាគ ៣.៩ ភាគរយ ក្នុងខែធ្នូ ឆ្នាំ ២០០២ ដល់ ២០០៦ អតិផរណាតម្លៃទំនិញប្រើប្រាស់ពីមួយឆ្នាំទៅមួយឆ្នាំ កើនដល់ ២៥.៧ ភាគរយ ក្នុងខែឧសភា ឆ្នាំ ២០០៨ ។ ទិន្នន័យចុងក្រោយ បានបង្ហាញថា សម្ពាធអតិផរណាមានភាពធូរស្បើយ ចាប់តាំងពីខែមិថុនា

---

[១] ចំពោះការពិភាក្សាបន្ថែម សូមមើល Edimon Ginting and Kelly Bird (2008), "ការវិភាគគណិតសាស្ត្រផ្អែកលើទិន្នន័យតួលេខចំពោះអតិផរណានៅក្នុងប្រទេសកម្ពុជា" ADB, Manila ។

មកម្លេះ ប៉ុន្តែអតិផរណានៅតែមានកម្រិតខ្ពស់ ២២.៣ ភាគរយ នៅក្នុងខែកក្កដា ។ ដោយសារកម្ពុជាជាសេដ្ឋកិច្ចបើកចំហរ[២] ស្ថិតក្នុង ទ្រង់ទ្រាយតូច និងមានការបើកព្រំដែនជាមួយប្រទេសវៀតណាម និងប្រទេសថៃផងនោះ ការប្រែប្រួលតម្លៃទំនិញជាអន្តរជាតិ ត្រូវបានគេរំពឹងទុកថា នឹងជះឥទ្ធិពលដ៏ធ្ងន់ធ្ងរដល់ដំណើរអតិផរណានៅក្នុងប្រទេសកម្ពុជា ។ ការរាលដាលនៃអតិផរណាពីដៃគូពាណិជ្ជកម្មរបស់ខ្លួន និងឥទ្ធិពលរបស់វាមកលើដំណើរអតិផរណានៅក្នុងប្រទេសកម្ពុជា មានទំនាក់ទំនងយ៉ាងសំខាន់ដល់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេស ។ ក្រោមរបបដុល្លារូបនីយកម្មបច្ចុប្បន្ននេះ តួនាទីនៃគោលនយោបាយហិរញ្ញវត្ថុ ប្រាកដជាស្ថិតនៅក្នុងព្រំដែនកំណត់មួយ ។ ប៉ុន្តែ អ្នកវិភាគជាច្រើនជឿជាក់ថា កំណើនដ៏ឆាប់រហ័សនៃបរិមាណរូបិយវត្ថុសរុបប្រៀបបានដូចជាការចាក់ប្រេង សាំងបន្ថែមទៅលើភ្លើងនៃអតិផរណាដែលកំពុងកើតមានឡើងក្នុងពេលបច្ចុប្បន្ននេះផងដែរ ។

៤. មានការរកឃើញពីរចំណុច ដែលគេគួរផ្តោតការយកចិត្តទុកដាក់ ។ ទីមួយ ការវិភាគបែបគណិតសាស្ត្រ ដែលបានធ្វើឡើងនៅក្នុងការសិក្សានោះ បានលើកឡើងថា ការរាលដាលនៃអតិផរណាពីដៃគូពាណិជ្ជកម្មរបស់ខ្លួន (វៀតណាម និងថៃ) ពិតជាមានតួនាទីដ៏ធំធេងក្នុងការពន្យល់ពីមូលហេតុនៃអតិផរណានៅក្នុងប្រទេសកម្ពុជា ជាពិសេសតាមរយៈតម្លៃម្ហូបអាហារ ដែលសុទ្ធតែជាមុខទំនិញអាចធ្វើពាណិជ្ជកម្មបាន ។ ការណ៍នេះកើតឡើងបានពីព្រោះតែមុខទំនិញពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា មានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយសេដ្ឋកិច្ចរបស់ប្រទេសថៃនិងប្រទេសវៀតណាមតាម រយៈការធ្វើពាណិជ្ជកម្មដ៏ច្រើនសន្ធឹកសន្ធាប់ ។ ទីពីរ អតិផរណាគោលក៏មានការកើនឡើងក្នុងចំនួនរង្វង់ ២-៣ ភាគរយដែរ ជាការបង្ហាញឱ្យឃើញថា កត្តាតម្រូវការ និង កត្តាក្នុងស្រុក ក៏មានតួនាទីក្នុងការពន្យល់អំពីអតិផរណានៃតម្លៃទំនិញក្នុងពេលបច្ចុប្បន្ននេះផងដែរ ។ ដោយឡែក កំណើនសាច់ប្រាក់ក៏ត្រូវបានគេរកឃើញថាពិតជាធ្វើឱ្យប៉ះពាល់ដល់អតិផរណាគោល ហើយផលប៉ះពាល់របស់វាកាន់តែមានសភាពខ្លាំងឡើងចាប់តាំងពីចុងឆ្នាំ ២០០៧ មក គឺនៅពេលដែលសេដ្ឋកិច្ចបានបង្ហាញពីសញ្ញានៃការកើនឡើងលឿនជ្រុលពេក ។ ហេតុដូច្នេះហើយ ជាការសំខាន់ណាស់ ដែលត្រូវត្រួតពិនិត្យអតិផរណាគោលនៅពេលធ្វើការវាយតម្លៃអំពីទំនោរនិងមូលហេតុអតិផរណា ។ ការវាយតម្លៃទៅលើអតិផរណាជារួម និងមូលហេតុរបស់វា អាចមើលរំលងកត្តាមូលហេតុខាងរូបិយវត្ថុ ។

៥. អត្ថបទសិក្សាជាបន្តទៅនេះ មានរៀបចំតាមលំដាប់លំដោយដូចតទៅនេះ : ផ្នែក II ធ្វើការពិភាក្សាទៅលើការប្រែប្រួលតម្លៃទំនិញនាពេលថ្មីៗនេះនៅក្នុងប្រទេសកម្ពុជា ។ ផ្នែក III ផ្តល់ការវិភាគផ្អែកលើទិន្នន័យតួលេខទៅលើអតិផរណានៅក្នុងប្រទេសកម្ពុជា ដោយលើកយកអតិផរណានាពេលបច្ចុប្បន្ននៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចបើកចំហរតិចតួច ដូចជាប្រទេសកម្ពុជា ។ ផ្នែកទី IV បង្ហាញនូវវិបាកជាគោលនយោបាយ និងសេចក្តីសន្និដ្ឋាន ។

---

[២] ការដោះដូរពាណិជ្ជកម្មជាផ្លូវការ មានចំនួនប្រហាក់ប្រហែលជា ១១០% នៃផ.ស.ស.នៅក្នុងឆ្នាំ ២០០៧ ។ ការនាំចូលពីប្រទេសវៀតណាម និងប្រទេសថៃ មានចំនួន ៣២ ភាគរយនៃការនាំចូលទាំងអស់របស់ប្រទេសកម្ពុជា ។ ភស្តុតាងផ្អែកលើការវិភាគផ្ទាល់ខ្លួន បានលើកឡើងថា តួលេខនាំចូលមិនផ្លូវការ មានចំនួនច្រើនជាងនេះ ពីព្រោះប្រទេសកម្ពុជាមានព្រំដែនដ៏វែងជាមួយប្រទេសទាំងពីរនេះ ។

## II. ការប្រែប្រួលតម្លៃទំនិញនាពេលបច្ចុប្បន្ន

៦. នៅក្នុងផ្នែកនេះ ការប្រែប្រួលតម្លៃទំនិញនាពេលបច្ចុប្បន្ន ត្រូវបានវាយតម្លៃតាមរយៈការគណនានូវការរួមចំណែកនៃមុខទំនិញសំខាន់ទីមួយៗនៅក្នុងសន្ទស្សន៍ថ្លៃលក់រាយក្នុងក្រុងភ្នំពេញ។ រង្វាស់អតិផរណាគោលសាមញ្ញចំនួនពីរ ត្រូវបានបង្កើតឡើងដើម្បីញែកផ្តាច់ផលប៉ះពាល់ពីម្ហូបអាហារ ប្រេងឥន្ធនៈ និងការដឹកជញ្ជូនដែលថ្លៃរបស់វាជារួមអាស្រ័យលើការផ្គត់ផ្គង់។ ការវិភាគរកឃើញថា ការកើនឡើងអតិផរណានាពេលថ្មីៗនេះជាចម្បងបណ្តាលមកពីការឡើងថ្លៃនូវថ្លៃម្ហូបអាហារ ថ្លៃប្រេងឥន្ធនៈ និងការដឹកជញ្ជូន។ ប៉ុន្តែ អតិផរណាគោល ក៏មានការកើនឡើងក្នុងចំនួន ២-៣ ភាគរយផងដែរ ជាការបង្ហាញឱ្យថា កត្តាតម្រូវការ និងកត្តាក្នុងស្រុកក៏មានតួនាទីជាមធ្យមក្នុងការពន្យល់អំពីអតិផរណាតម្លៃទំនិញក្នុងពេលបច្ចុប្បន្ននេះ។ នៅក្នុងការវាយតម្លៃឥទ្ធិពលជាសក្តានុពលនៃកត្តាតម្រូវការ និងកត្តាក្នុងស្រុកមកលើអតិផរណា យើងបានចាប់ផ្តើមដោយធ្វើការវាយតម្លៃលើទំនោរនៃគម្លាតទិន្នផល (ពោលគឺ ភាពខុសគ្នារវាង ផ.ស.ស.ដែលមានសក្តានុពល និងផ.ស.ស.ពិត) ដើម្បីវាយតម្លៃថា តើសេដ្ឋកិច្ចកំពុងតែបង្ហាញសញ្ញា "កើនជ្រុលពេក" នៅក្នុងឆ្នាំ ២០០៧ នេះដែរឬទេ។ បន្ទាប់មកទៀត យើងត្រួតពិនិត្យកត្តាទាំងឡាយណាដែលអាចជះឥទ្ធិពលដល់សក្តានុពលនៃសេដ្ឋកិច្ចដែលកើនលឿនជ្រុលពេក ដូចជាកំណើនជាបរិមាណរូបិយវត្ថុសរុប និងគោលនយោបាយសារពើពន្ធ។ លទ្ធផលនៃការវាយតម្លៃបានចង្អុលបង្ហាញថា សេដ្ឋកិច្ចកំពុងបង្ហាញនូវសញ្ញាកើនលឿនជ្រុលពេក ហើយអាចជម្រុញឱ្យមានការកើនឡើងនូវអតិផរណាគោលផងដែរ ។

### កត្តារួមចំណែកដល់អតិផរណាតម្លៃទំនិញ នាពេលបច្ចុប្បន្ន

រូបភាព ១

កត្តារួមចំណែកនាំឱ្យមានអតិផរណា ២០០២-២០០៨

(គិតជាភាគរយ)




ប្រភព : វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់បុគ្គលិក ADB

៧. **ការកើនឡើងថ្លៃម្ហូបអាហារ គឺជាកត្តារួមចំណែកនាំឱ្យមានការកើនឡើងនូវអតិផរណាក្នុងពេលបច្ចុប្បន្ននេះ។** តាំងពីដើមរៀងមក មុខទំនិញម្ហូបអាហារ តែងតែរួមចំណែកយ៉ាងសំខាន់ដល់អតិផរណាតម្លៃទំនិញនៅក្នុងប្រទេសកម្ពុជា។ ការរួមចំណែកនៃមុខទំនិញទាំងនេះ មានការកើនឡើងជាលំដាប់គួរឱ្យកត់សម្គាល់ចាប់ពី ២.៧ ភាគរយនៅ ក្នុងឆ្នាំ ២០០៦ ដល់ ៩ភាគរយ នៅក្នុងឆ្នាំ២០០៧។ នៅពេលដែលមានការកើនឡើងដល់កំពូលកាលពីខែឧសភា ឆ្នាំ ២០០៨ មុខទំនិញជាម្ហូបអាហារបានរួមចំណែករហូតដល់ ២១ ភាគរយ ដែលចំនួននេះលើសពី ៨០ភាគរយនៃអតិផរណាសរុបប្រចាំខែទៅទៀត។ ការបន្តឡើងតម្លៃប្រេងឥន្ធនៈ ក៏បានជម្រុញឱ្យអតិផរណាមានការកើនឡើងបន្ថែមទៀតតាមរយៈវិស័យដឹកជញ្ជូន។ ការរួមចំណែកពីមុខទំនិញសំខាន់ផ្សេងៗទៀត ដូចជា ទឹក ភ្លើង ការថែរក្សាសុខភាព ការអប់រំ និងរបស់របរប្រើប្រាស់ប្រចាំថ្ងៃផ្សេងៗទៀត គឺមានចំនួនតិចតួចប៉ុណ្ណោះ និងមានសភាពថេរទៀតផង មួយផ្នែកដោយសារតែរដ្ឋាភិបាលជាអ្នកគ្រប់គ្រងថ្លៃអគ្គិសនី និងមិនបានតម្លើងថ្លៃចាប់តាំងពីខែកុម្ភៈ ឆ្នាំ ២០០៦ មកម្លេះ។ ការស្នាក់នៅ (ការជួល) -កត្តាដ៏ធំទីពីរ

(២៧.៣ ភាគរយ) បន្ទាប់ពីម្ហូបអាហារនៅក្នុងសន្ទស្សន៍ថ្លៃទំនិញរាយក្នុងក្រុងភ្នំពេញ ក៏មានការកើនឡើងរហូតដល់ប្រមាណជា ៤ ភាគរយដែរ ចាប់តាំងពីខែមករា ឆ្នាំ ២០០៨ ប៉ុន្តែមានអត្រាទាបជាងច្រើន បើប្រៀបជាមួយនឹងអតិផរណាសរុបទាំងអស់[៣] ។

៨. **អតិផរណាតម្លៃម្ហូបអាហារនៅក្នុងប្រទេសកម្ពុជា ដើរយ៉ាងកៀកគ្នានិងអតិផរណានៅក្នុង ប្រទេសថៃ និងប្រទេសវៀតណាម (រូបភាព ២)** អតិផរណាតម្លៃម្ហូបអាហារនៅក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមដើរតាមទំនោរនៃតម្លៃទំនិញអន្តរជាតិចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០០៧ មកម្លេះ។ ប៉ុន្តែវាជាការគួរឱ្យ ចាប់អារម្មណ៍ដែរនៅពេលយើងឃើញថា អតិផរណាតម្លៃម្ហូបអាហារនៅក្នុងប្រទេសកម្ពុជា បានដើរប្រកៀកគ្នានឹងអតិផរណាតម្លៃម្ហូបអាហារ នៃដៃគូពាណិជ្ជកម្មសំខាន់ទាំងពីររបស់ខ្លួន (ប្រទេសថៃ និងវៀតណាម) ជាជាងជាមួយនិងតម្លៃម្ហូបអាហារអន្តរជាតិ ចាប់តាំង ពីឆ្នាំ២០០៣ មកម្លេះ។ នេះមានន័យថា ការនាំចេញនាំចូលម្ហូបអាហារទ្រង់ទ្រាយធំតាមច្រកព្រំដែន ធ្វើឱ្យមានតុល្យភាពតម្លៃទំនិញក្នុងកម្រិតណាមួយនោះ រវាងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មសំខាន់ទាំងពីររបស់ខ្លួន។ ហេតុដូច្នេះហើយ ការប្រែប្រួលតម្លៃម្ហូបអាហារនៅក្នុងប្រទេស ទាំងពីរនេះ ពិតជាមានភាពជាប់ទាក់ទងដោយផ្ទាល់ក្នុងការពន្យល់ពីអតិផរណាក្នុងប្រទេសកម្ពុជា ជាជាងជាមួយនឹងសូចនាករតម្លៃម្ហូបអាហារអន្តរជាតិ។ ភស្តុតាងស្ថិតិនៃចំណងទាក់ទងដ៏ខ្លាំងជាមួយនិងអតិផរណាក្នុងតំបន់ មានបង្ហាញជូននៅខាងក្រោម (កថាខ័ណ្ឌទី ១៥) ។ រូបភាពទី៣ បានផ្តល់ នូវភស្តុតាងបន្ថែមអំពីទំនាក់ទំនងនៃតម្លៃម្ហូបអាហាររបស់ប្រទេសកម្ពុជា ជាមួយនិងប្រទេសថៃ និងប្រទេសវៀតណាម។ ផ្ទាំង "ក" បង្ហាញនូវគម្លាតនៃខ្សែកោងអតិផរណរួមរបស់ប្រទេសកម្ពុជាចេញពីខ្សែកោងអតិផរណារបស់ប្រទេសថៃ និងប្រទេសវៀតណាម (ពោលគឺ វាបានឃ្លាតគ្នាចាប់ពីចំណុចសូន្យទៅ) ។ ផ្ទាំង "ខ" បង្ហាញនូវគម្លាតនៃអតិផរណា តម្លៃម្ហូបអាហារ។ ដូចឃើញក្នុងផ្ទាំង "ក" អតិផរណារួមរបស់ប្រទេសកម្ពុជាមានអត្រាទាបជាងអតិផរណារបស់ប្រទេសថៃ និងប្រទេសវៀតណាម ដែលគេគិតតាមមធ្យមភាគទម្ងន់សម្រាប់ឆ្នាំ ២០០៣ ដល់ឆ្នាំ ២០០៧។ តេស្តបែបស្ថិតិទៅលើទំនោរ នៃស៊េរីអតិផរណាទាំងពីរ បានបង្ហាញនូវដំណើរស្របគ្នា

**រូបភាព ២**

**អតិផរណាតម្លៃទំនិញ និងម្ហូបអាហារ**

**(បម្រែបម្រួលគិតជា %មូលដ្ឋានឆ្នាំលើឆ្នាំ)**




ប្រភព : CEIC, IMF, និងការគណនារបស់បុគ្គលិក ADB

---

[៣] អតិផរណាតម្លៃម្ហូបអាហារ មិនមែនកើតឡើងតែនៅក្នុងប្រទេសកម្ពុជាតែមួយប៉ុណ្ណោះទេ ។ មានបណ្តាប្រទេសផ្សេងទៀតនៅក្នុងតំបន់ ក៏ប្រឈមនឹងសំពាធអតិផរណាស្រដៀងគ្នានេះផងដែរកាលពីដើមឆ្នាំ 2008 ដែលបង្កឡើងដោយការកើនឡើងនូវតម្លៃទំនិញជាសាកលនេះ។ ទោះជាដូច្នេះក៏ដោយ ក៏អតិផរណាម្ហូបអាហារក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ 2008 មានការកើនឡើងខ្ពស់នៅក្នុងតំបន់អាស៊ីនេះផងដែរ ។

តិចតួច នៃខ្សែស៊េរីទាំងពីរមានន័យថា មានទំនាក់ទំនងគ្នាតិចតួចនៅក្នុង រយៈពេលវែង[៤] ។ ផ្ទុយមកវិញអតិផរណាតម្លៃម្ហូបអាហាររបស់ប្រទេសកម្ពុជា មានការកើនឡើងប្រហាក់ប្រហែលនឹងអតិផរណារបស់ប្រទេសថៃ និងប្រទេសវៀតណាមដែរ ដូចដែលបានបង្ហាញតាមរយៈ គម្លាតរបស់វាចេញពីចំណុចសូន្យ ។ តេស្តបែបស្ថិតិបញ្ជាក់ថា អតិផរណាថ្លៃម្ហូបអាហាររបស់ប្រទេសកម្ពុជា នឹងធ្វើដំណើរទៅរកចំណុចប្រសព្វជាមួយ និងអតិផរណាថ្លៃម្ហូបអាហាររបស់ប្រទេសថៃ និងប្រទេសវៀតណាមក្នុងរយៈពេលវែង (ពោលគឺអតិផរណានៅក្នុងប្រទេសទាំងបីមានការផ្សារភ្ជាប់គ្នាយ៉ាងខ្លាំង) ។ ទំនោរនៃតួលេខអតិផរណារួម និងអតិផរណាថ្លៃម្ហូបអាហារ បានធ្វើដំណើរបញ្ច្រាសទិសគ្នាវិញនៅក្នុងឆ្នាំ ២០០៨ ។ មូលហេតុដែលនាំឱ្យមានការធ្វើដំណើរឃ្លាតគ្នា នឹងមានបកស្រាយនៅផ្នែកបន្ទាប់នេះ ។

**រូបភាព៣: គម្លាតអតិផរណារបស់ប្រទេសកម្ពុជាចេញពីអតិផរណារបស់ដៃគូពាណិជ្ជកម្មរបស់ខ្លួន**




ប្រភព: ការគណនារបស់បុគ្គលិករបស់ ADB

៩. **អតិផរណានៃមុខទំនិញចាំបាច់ :** មានការទទួលស្គាល់ជាទូទៅថា ជារឿយៗ អតិផរណានៃសន្ទស្សន៍តម្លៃទំនិញ អាចជាសូចនាករមិនត្រឹមត្រូវនៃអតិផរណាជាមូលដ្ឋាន ។ ហេតុដូច្នេះហើយ បានជាធនាគារកណ្តាលជាច្រើន យល់ឃើញថាជាការចាំបាច់ណាស់ក្នុងការតាមដានរង្វាស់អតិផរណានៃមុខទំនិញចាំបាច់ ដែលវាបានញែកការឡើងគំហុកនៃតម្លៃជាបណ្តោះអាសន្ននេះ ចេញពីដំណើរអតិផរណា ហេតុដូច្នេះ នឹងនាំឱ្យមានការបង្ហាញនូវស្ថានភាពថ្លៃទំនិញកាន់តែត្រឹមត្រូវ ។ អតិផរណានៃមុខទំនិញចាំបាច់មានសារៈប្រយោជន៍ ពីរយ៉ាងនៅក្នុងការអនុវត្តនយោបាយហិរញ្ញវត្ថុ ។ ទីមួយ ដោយហេតុថា អតិផរណានៃមុខទំនិញចាំបាច់ មិនបានរាប់បញ្ចូលការប្រែប្រួលតម្លៃបណ្តោះអាសន្នដែលកើតឡើងដោយសារបញ្ហានៃការផ្គត់ផ្គង់នោះ (Ball and Mankiw (2004) and Roger, 1997), ដូច្នេះអតិផរណានៃមុខទំនិញចាំបាច់ (អតិផរណាគោល) នេះ អាចត្រូវបានចាត់ទុកថា ជារង្វាស់អតិផរណាមួយ

---

[៤] តេស្តនេះ សំដៅទៅលើតេស្តទាំងឡាយណាដែលបានបញ្ចូលរួមគ្នា ។ តេស្តទាំងនេះ ត្រូវបានគេប្រើដើម្បីកំណត់ថាតើអតិផរណារបស់ប្រទេសកម្ពុជាធ្វើដំណើរស្រប ឬក៏ប្រសព្វជាមួយនិងអតិផរណារបស់ដៃគូពាណិជ្ជកម្មរបស់ខ្លួននៅក្នុងរយៈពេលវែង ។

ដែលជាលទ្ធផលបានមក ពីគោលនយោបាយ ហេតុដូច្នេះ អតិផរណាគោលនេះ ងាយស្រួលក្នុងការគ្រប់គ្រងដោយអាជ្ញាធររូបិយវត្ថុ។ ទីពីរ ពីព្រោះតែគោលនយោបាយរូបិយវត្ថុ ជះឥទ្ធិពលដល់សកម្មភាពសេដ្ឋកិច្ច តែត្រូវប្រើរយៈពេលយូរ ហើយអាចនឹងប្រែប្រួលទៀតនោះ ដូច្នេះវាមិនមែនជាឧបករណ៍ល្អទេក្នុងការទប់ទល់នឹងស្ថានភាពថ្លៃទំនិញជាបណ្ដោះអាសន្ននោះ ដូច្នេះ អ្នកបង្កើតគោលនយោបាយ មានចំណាប់អារម្មណ៍លើការប្រមើលអតិផរណាច្រើនជាង។ នៅក្នុងកម្រិតដែលរង្វាស់អតិផរណាគោលអាចញែកទំនោរអតិផរណា ជាមូលដ្ឋានដែលគង់នឹងវិលតាមលំអាននេះវិញឱ្យជាច់ដោយឡែកបាន រង្វាស់ទាំងនោះ អាចក្លាយជាត្រីវិស័យដ៏មានប្រយោជន៍ ក្នុងរយៈពេលខ្លីសម្រាប់ព្យាករណ៍អតិផរណា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នាពេលអនាគត។

១០. មានអ្នកវិភាគមួយចំនួនជឿជាក់ថាការកើនឡើងនូវកំណើននៃរូបិយវត្ថុខ្លាំង ពិតជារួមចំណែកនាំឱ្យមានការកើនឡើងនូវអតិផរណា នាពេលបច្ចុប្បន្ននេះនៅក្នុងប្រទេសកម្ពុជា។ ការវិភាគទៅលើរង្វាស់អតិផរណាគោលពិតជាមានសារៈប្រយោជន៍ក្នុងការឆ្លើយតបទៅនឹងសំណួរថា តើកំណើនរូបិយវត្ថុពិតជាបណ្ដាលឱ្យមានអតិផរណានៅក្នុងប្រទេសកម្ពុជាដែរ ឬក៏អត់ ហើយក្នុងកម្រិតណា? យើងបានបង្កើតរង្វាស់អតិផរណាគោលចំនួនពីរសម្រាប់ប្រទេសកម្ពុជា ដើម្បីអាចឱ្យយើងធ្វើការវិភាគទៅលើចលនាថ្លៃទំនិញជាមូលដ្ឋាន។ រង្វាស់ទីមួយ ត្រូវបានកំណត់ឡើងដោយមិនរាប់បញ្ចូលមុខទំនិញម្ហូបអាហារ (core_EF) ដែលមានមធ្យមទម្ងន់ប្រមាណជា ៣៩ ភាគរយ នៅក្នុងសន្ទស្សន៍ថ្លៃទំនិញរាយក្នុងក្រុងភ្នំពេញ។ រង្វាស់ទីពីរ មិនរាប់បញ្ចូលម្ហូបអាហារ ប្រេងសាំង និងការដឹកជញ្ជូនទេ (core_ EFFT) ដែលមានមធ្យមទម្ងន់ប្រមាណជា ៤៤ ភាគរយ នៅក្នុងសន្ទស្សន៍ថ្លៃទំនិញរាយ ក្នុងក្រុងភ្នំពេញ (សូមមើល ឧបសម្ព័ន្ធ ១ សម្រាប់ការគណនារង្វាស់អតិផរណាគោល)។

១១. **អតិផរណាគោល គឺមានកម្រិតទាបជាងអតិផរណារួមច្រើន ជាការបញ្ជាក់ថា តម្លៃម្ហូបអាហារគឺជាមូលហេតុចម្បងដែលនាំឱ្យមានកំណើនអតិផរណានាពេលថ្មីៗនេះ។** រូបភាព ៤ បង្ហាញនូវអតិផរណារួម និងរង្វាស់អតិផរណាគោលចំនួនពីរ។ ដូចបានឃើញ គម្លាតរវាងអត្រាអតិផរណារួមនិងរង្វាស់អតិផរណាគោលទាំងពីរ មានសភាពកាន់តែឃ្លាតគ្នាទៅៗ បន្ទាប់ពីខែកក្កដា ឆ្នាំ ២០០៧ គឺចង់និយាយថា ការកើនឡើងដ៏ឆាប់រហ័សនៃតម្លៃម្ហូបអាហារ គឺជាមូលហេតុដ៏សំខាន់នៃការកើនឡើងអតិផរណា។ គម្លាតរវាងអតិផរណាគោលមិនរាប់បញ្ចូលម្ហូបអាហារ (core_EF) និង អតិផរណាគោលមិនរាប់បញ្ចូល

រូបភាព ៤ : រង្វាស់តិផរណាគោល ២០០៣-២០០៨




ប្រភព : វិទ្យាស្ថានជាតិស្ថិតិកម្ពុជា និងការគណនារបស់បុគ្គលិក ADB

ម្ហូបអាហារ ប្រេងឥន្ធនៈ និងការដឹកជញ្ជូន (core_EFFT) (ដែលមិនរាប់បញ្ចូលថាមពល និងការដឹកជញ្ជូន) ក៏រីកគម្លាតពីគ្នាផងដែរ នៅក្នុងឆ្នាំ ២០០៨ មានន័យថា តម្លៃនៃប្រេងសាំង និងការដឹកជញ្ជូន ក៏ជាប្រភពសំខាន់នាំឱ្យមានអតិផរណាផងដែរ ។

១២. **អតិផរណាគោល បានកើនឡើងនៅដំណាច់ឆ្នាំ ២០០៧ បញ្ជាក់ឱ្យឃើញថា ផលប៉ះពាល់នៅក្នុងជុំទីពីរ ក៏កើតមានឡើងដែរ ។** ទោះបីជាតម្លៃម្ហូបអាហារ ប្រេងសាំង និងការដឹកជញ្ជូន ទំនងជាមានតួនាទីសំខាន់ក្នុងការពន្យល់ពីដំណើរអតិផរណានាពេលថ្មីៗនេះក៏ដោយ ក៏ទំនោរនៃអតិផរណាគោលនាពេលថ្មីៗ ចង្អុលឱ្យឃើញថា កត្តាក្នុងស្រុក ក៏មានតួនាទីរួមចំណែកជាបង្គួរដែរ ។ អតិផរណាគោលមានការកើនឡើងជាលំដាប់ចាប់តាំងពីចុងឆ្នាំ ២០០៧ មក ជាការបង្ហាញឱ្យឃើញថា ការរំពឹងទុកថានឹងមានអតិផរណា មានការកើនឡើង ហើយឥទ្ធិពលជាបន្ទាប់ដែលត្រូវបានរុញច្រានដោយសារអតិផរណាលើពិភពលោកនោះ ក៏បានរីករាលដាលទៅដល់វិស័យមិនមែនសម្រាប់ពាណិជ្ជកម្មផ្សេងទៀត ។

១៣. **កត្តាតម្រូវការ អាចមានតួនាទីនាំឱ្យមានការកើនឡើងនូវអតិផរណានៃមុខទំនិញចាំបាច់ក្នុងចុងឆ្នាំ ២០០៧ ។** រង្វាស់មួយសម្រាប់វាស់វែងសំពាធតម្រូវការក្នុងស្រុកដែលមានទៅលើអតិផរណា គឺគម្លាតទិន្នផល ដែលវាស់វែងនូវភាពខុសគ្នារវាងទិន្នផលជាក់ស្តែង (ផ.ស.ស. ពិត) និងការព្យាករណ៍នៃទិន្នផលដែលមានសក្តានុពល ។ គម្លាតទិន្នផលវិជ្ជមាន គឺជាការបង្ហាញអំពីសម្ពាធតម្រូវការ ដែលមានភាពលើសលប់នៅក្នុងវិស័យសេដ្ឋកិច្ច ។ រូបភាព ៥ បង្ហាញនូវតួលេខផ.ស.ស.ពិត ដែលមានចំនួនជិតស្មើទៅនឹង ផ.ស.ស. សក្តានុពលចាប់ពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០០៦ ។ ក៏ប៉ុន្តែ នៅឆ្នាំ ២០០៧ មានភស្តុតាងមិនទាន់ច្បាស់លាស់មួយ បានបង្ហាញថា ផ.ស.ស.ពិត បានងាកចេញពីផ្លូវកំណើនសក្តានុពលក្នុងកម្រិតគួរឱ្យកត់សម្គាល់ ដែលនេះបង្កឡើងមួយផ្នែកដោយកំណើនដ៏ខ្ពស់នៃបរិមាណរូបិយវត្ថុសរុប និងការឱ្យខ្ចីប្រាក់របស់ធនាគារពាណិជ្ជ (រូបភាព ៦) ។ រូបិយវត្ថុសរុបបានកើនឡើងចំនួន ៦១% ប្រចាំឆ្នាំនាឆ្នាំ ២០០៧ កន្លងទៅ ដោយសារលំហូរចូលមូលធនដ៏ច្រើនសន្ធឹកសន្ធាប់ ប៉ុន្តែបានធ្លាក់ចុះបន្តិចមកត្រឹម ៤០% កាលពីខែកក្កដា ឆ្នាំ ២០០៨ ។ កំណើនសាច់ប្រាក់ (M1)—ដែលជាអញ្ញត្តិកំណត់ (Determinant) អតិផរណាមានលក្ខណៈប្រសើរជាងបរិមាណផ្គត់ផ្គង់រូបិយវត្ថុទូទៅ បានកើនឡើងបន្ថែមទៀតពី ២០% កាលពីខែធ្នូ ឆ្នាំ ២០០៧ ដល់ ៤៣% (មូលដ្ឋានប្រចាំឆ្នាំ) កាលពីខែ កក្កដា ឆ្នាំ ២០០៨ ។ ប្រាក់កម្ចីដល់វិស័យឯកជន បានកើនឡើងដល់កម្រិតខ្ពស់បំផុតមិនធ្លាប់មាន ពោលគឺ ៧៦% កាលពីខែធ្នូ ឆ្នាំ ២០០៧ ប៉ុន្តែក៏មានការធ្លាក់ចុះបន្តិចមកវិញនៅក្នុងឆ្នាំ ២០០៨ ត្រឹមអត្រា ៣៥% ប៉ុណ្ណោះកាលពីខែកក្កដា ឆ្នាំ ២០០៨ ។

**រូបភាព ៥: គម្លាតទិន្នផល**




ប្រភព : វិទ្យាស្ថានជាតិស្ថិតិកម្ពុជា។ ផ.ស.ស. សក្តានុពល ត្រូវបានព្យាករណ៍ដោយប្រើប្រាស់ប្រព័ន្ធ Hodrick-Prescott (HP) ដែលសម្រាប់ព្យាករណ៍និន្នាការមិនមែនលីនីអ៊ែ នៅក្នុងទិន្នន័យផ.ស.ស.។

**រូបភាព ៦: បរិមាណរូបិយវត្ថុ និងកម្ចីវិស័យឯកជន**

( កំណើនប្រចាំឆ្នាំ )




ប្រភព: ធនាគារជាតិនៃកម្ពុជា និងការគណនារបស់បុគ្គលិក ADB

១៤. **គោលនយោបាយសារពើពន្ធដែលមានលក្ខណៈប្រយ័ត្នប្រយែង ជួយសម្រាលសម្ពាធតម្រូវការ។** គោលនយោបាយសារពើពន្ធ ទំនងជាអាចជួយកាត់បន្ថយបាននូវផលប៉ះពាល់លើសេដ្ឋកិច្ចក្នុងឆ្នាំ ២០០៧ និង ២០០៨។ អតិរេកថវិកា នាពេលបច្ចុប្បន្ន បានកើនដល់ ៣.១% នៃផ.ស.ស.នៅក្នុងឆ្នាំ ២០០៧ គឺកើនពី ១.២%នៃផ.ស.សកាលពីឆ្នាំ ២០០៦ ហើយឱនភាពថវិកាសរុបបានធ្លាក់ចុះនៅក្នុងឆ្នាំ ២០០៧។ ឱនភាពសរុបសម្រាប់ឆមាសទីមួយនៃឆ្នាំ ២០០៨ ត្រូវបានព្យាករណ៍ទុកថា មានចំនួន 0.៤% នៃ ផ.ស.ស. ដែលធ្លាក់ចុះពីអត្រា ២.៨% កាលពីឆ្នាំ ២០០៧។ តាមរយៈការចង្អុលបង្ហាញពីអតិរេកនាពេលបច្ចុប្បន្ន រដ្ឋាភិបាលបានបង្គរទុកនូវប្រាក់បញ្ញើនៅក្នុងធនាគារជាតិនៃកម្ពុជា ដោយមានចំនួនកើនឡើងដល់ ៦% នៃផ.ស.សកាលពីខែធ្នូ ឆ្នាំ ២០០៧ ហើយប្រាក់បង្គរទុកនេះ នៅតែបន្តកើនរហូតដល់ដំណាច់ឆ្នាំ ២០០៨។

## III. មូលហេតុអតិផរណានៅក្នុងប្រទេសកម្ពុជា

១៥. ការវិភាគដែលបានបង្ហាញជូនខាងលើ រកឃើញថា អតិផរណារបស់ដៃគូពាណិជ្ជកម្ម មានតួនាទីសំខាន់ណាស់ក្នុងការពន្យល់ពីអតិផរណានៃមុខទំនិញម្ហូបអាហារនៅក្នុងប្រទេសកម្ពុជា។ ទោះជាដូច្នេះក៏ដោយ ក៏អតិផរណារួមនៅក្នុងប្រទេសកម្ពុជា ធ្វើដំណើរស្របតែបន្តិចបន្តួចប៉ុណ្ណោះជាមួយ និងអតិផរណារួមគិតជាមធ្យមទម្ងន់របស់ប្រទេសដែលជាដៃគូពាណិជ្ជកម្មរបស់ខ្លួន។ ដំណើរស្របគ្នាត្រឹមតែបន្តិចបន្តួចនេះ មានន័យថា កត្តាក្នុងស្រុកផ្សេងទៀត ក៏មានសារៈសំខាន់ផងដែរ សម្រាប់ការពន្យល់ពីដំណើរអតិផរណានៅក្នុងប្រទេសកម្ពុជាតាមរយៈទំនិញមិនអាចធ្វើពាណិជ្ជកម្មបាន។ នៅក្នុងផ្នែកនេះ កត្តាដែលជះឥទ្ធិពលដល់ដំណើរអតិផរណានៅក្នុងប្រទេសកម្ពុជា នឹងត្រូវបានពិនិត្យឱ្យបានជាក់ច្បាស់បន្ថែមទៀត។ កត្តាទាំងនោះ រួមមានអតិផរណារបស់ដៃគូពាណិជ្ជកម្ម អត្រាប្តូរប្រាក់ និង កំណើនបរិមាណរូបិយវត្ថុសរុប។ រង្វាស់អតិផរណាគោល ត្រូវបានគេរំពឹងទុកថា នឹងទទួលរងនូវ

ឥទ្ធិពលច្រើនពីកត្តាក្នុងស្រុក ដូចជា កំណើនបរិមាណរូបិយវត្ថុសរុបជាដើម ។ល ។ ហេតុដូច្នេះហើយ ម៉ូដែលដាច់ដោយឡែកមួយក៏ត្រូវបានគេធ្វើតេស្តសម្រាប់វង្វាស់អតិផរណាគោលនេះផងដែរ ។ ម៉ូដែលគណិតសាស្ត្រផ្អែកលើទិន្នន័យតួលេខ ដែលមានបង្ហាញនៅក្នុងការសិក្សានេះ បានផ្អែកមូលដ្ឋានលើការសិក្សានាពេលថ្មីៗស្តីពីអតិផរណានៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចតូច និងបើកចំហរ ។

១៦. ម៉ូដែលអតិផរណាដែលបានបង្ហាញនៅទីនេះ បានញែកផលប៉ះពាល់ក្នុងរយៈពេលខ្លីឱ្យដាច់ចេញពីអញ្ញត្តិកំណត់ (Determinant) រយៈពេលវែងនៃអតិផរណានៅក្នុងប្រទេសកម្ពុជា ។ គេរំពឹងទុកថា នឹងមានការកើនឡើងថ្លៃគំហុកជាបណ្តោះអាសន្នខ្លះ ដែលជះឥទ្ធិពល ដល់អតិផរណាក្នុងរយៈពេលខ្លី ប៉ុន្តែឥទ្ធិពលនេះ នឹងរលាយបាត់បន្តិចម្តងៗក្នុងរយៈពេលវែង ។

**១៧. ដើម្បីពិនិត្យមើលកត្តាទាំងនេះ រូបមន្តម៉ូដែលសម្រាប់រយៈពេលវែង ដូចខាងក្រោម ត្រូវបានបង្កើតឡើង :**

$$\pi_t^{CAM} = (\pi_t^{INT}, ER_t^{INT}, M1_t, D_t)$$

(1)

$\pi_t^{CAM}$ គឺជាបម្រែបម្រួលអតិផរណាតម្លៃទំនិញគិតជាភាគរយប្រចាំឆ្នាំ នៅក្នុងប្រទេសកម្ពុជា ។

$ER_t^{INT}$ គឺជាបម្រែបម្រួលអត្រាប្តូរប្រាក់របស់ដៃគូពាណិជ្ជកម្មគិតជាភាគរយប្រចាំឆ្នាំគិតជាមធ្យមទម្ងន់ធៀបទៅនឹងប្រាក់ដុល្លារអាមេរិក ។ ដោយសារប្រទេសកម្ពុជា គឺជាប្រទេសដែលសេដ្ឋកិច្ចប្រើប្រាស់ដុល្លារច្រើន អត្រាប្តូរប្រាក់សមស្របដែលប្រើប្រាស់នៅក្នុងម៉ូដែលនេះ គឺជាអត្រាប្តូរប្រាក់របស់ដៃគូពាណិជ្ជកម្មរបស់ខ្លួន ( ប្រទេសថៃ និងប្រទេសវៀតណាម) ធៀបទៅនឹងប្រាក់ដុល្លារអាមេរិក មិនមែនធៀបនឹងប្រាក់រៀលរបស់កម្ពុជាទេ ។

$M1_t$ គឺជាកំណើនសាច់ប្រាក់ប្រចាំឆ្នាំ ដែលជាអញ្ញត្តិកំណត់អតិផរណាមានលក្ខណៈប្រសើរជាងរូបិយវត្ថុទូទៅ ។

D1 គឺជាអថេរមិនពិតដើម្បីពិនិត្យមើលទៅលើគម្លាតនៃទិន្នផលលើស ដែលកើតមាននៅក្នុងឆ្នាំ ២០០៧ ។ អន្តរសកម្ម រវាង D1 នឹងអថេរផ្សេងទៀត ក៏នឹងត្រូវត្រួតពិនិត្យផងដែរ ។

**១៨. យើងបានព្យាករណ៍នូវទំនាក់ទំនងខាងក្រោមជាមួយនឹង $\pi_t^{CAM}$ :**

- $\pi_t^{INT}$ កើនឡើង មានន័យថា $\pi_t^{CAM}$ កើនឡើងដែរ ។
- $ER_t^{INT}$ ធ្លាក់ចុះ មានន័យថា $\pi_t^{CAM}$ កើនឡើង ។ $ER_t^{INT}$ ធ្លាក់ចុះ បង្ហាញនូវការធ្លាក់ចុះតម្លៃប្រាក់ដុល្លាររបស់អាមេរិកធៀបនឹងរូបិយប័ណ្ណរបស់ដៃគូពាណិជ្ជកម្មរបស់ខ្លួន ។ ត្រលប់មកវិញ មានន័យថាកម្ពុជាកំពុងប្រឈមទៅនឹងតម្លៃទំនិញដែលធ្វើពាណិជ្ជកម្មជាអន្តរជាតិខ្ពស់ ហេតុដូច្នេះ បណ្តាលឱ្យមានអតិផរណាក្នុងស្រុកខ្ពស់ ។
- $M1_t$ កើនឡើង មានន័យថា $\pi_t^{CAM}$ កើនឡើងដែរ ។
- D1 ត្រូវបានព្យាករណ៍ទុកថា នឹងមានសញ្ញាវិជ្ជមាន ។

១៩. ចលនាអតិផរណាក្នុងរយៈពេលខ្លីនៅក្នុងប្រទេសកម្ពុជា ត្រូវបានវាយតម្លៃដោយមើលទៅការបម្រែបម្រួលនៃអថេរដែលមាននៅក្នុងសមីការ (១) បូកជាមួយនិងអញ្ញត្តិគ្រាមុន (lagged terms) និងបន្ទាប់មកបន្ថែមអញ្ញត្តិកែតម្រូវកំហុស (error correction term [ECM]) :

$$\Delta\pi_t^{CAM} = \sum_{j=1}^{m}\alpha_j \Delta\pi_{t-j}^{CAM} + \sum_{j=1}^{n}\beta_j \Delta\pi_{t-j}^{INT} + \sum_{j=1}^{n}\delta_j \Delta ER_{t-j}^{INT} + \sum_{j=1}^{n}\kappa_j \Delta M1_{t-j}^{INT} - \gamma(ECM_{t-1}) + \varepsilon_t \qquad (2)$$

ដែល $ECM_{t-1} = (\pi_{t-1}^{CAM} - \beta_j \pi_{t-1}^{INT} - \delta_j ER_{t-1} - \kappa_j M1_{t-1})$ តំណាងឱ្យប៉ារ៉ាម៉ែត្រកែតម្រូវ។ ប្រសិនបើមេគុណ របស់ ECM តិចជាង ១ នេះមានន័យថា អតិផរណារបស់ប្រទេសកម្ពុជា អាចស្ថិតក្នុងទិសដៅផ្ទុយពីអតិផរណារបស់ដៃគូពាណិជ្ជកម្មរបស់ខ្លួនក្នុងរយៈពេលខ្លី ប៉ុន្តែនឹងប្រសព្វគ្នាវិញក្នុងរយៈពេលវែង។ ប៉ារ៉ាម៉ែត្រ ECM អាចយកមកប្រើដើម្បីគណនាល្បឿននៃការកែតម្រូវ ឬចំនួនខែដែលការឡើងជាគំហុកនូវតម្លៃទំនិញត្រូវការដើម្បីឱ្យវាវិលមកជួបប្រសព្វគ្នាឡើងវិញក្នុងទំនាក់ទំនងរយៈពេលវែងវិញ។

២០. ទិន្នន័យសាច់ប្រាក់ គឺទទួលបានពីធនាគារជាតិនៃកម្ពុជា ហើយទិន្នន័យអត្រាប្តូរប្រាក់របស់ប្រទេសវៀតណាម និងប្រទេសកម្ពុជា ទទួលបានពី CEIC។ ម៉ូដែលនេះ ធ្វើការព្យាករណ៍សម្រាប់ឆ្នាំ ២០០៣:១២ ដល់ ២០០៨:៧ ដោយសារទិន្នន័យជាស៊េរីដែលមានតាមឆ្នាំនោះ មានតិចតួចសម្រាប់ប្រទេសកម្ពុជា។ លទ្ធផលប៉ាន់ស្មានសម្រាប់ម៉ូដែលក្នុងរយៈពេលវែង និងខ្លីមានបង្ហាញជូននៅក្នុង តារាង ១។

**តារាង ១ : ទំនាក់ទំនងរយៈពេលវែង និងរយៈពេលខ្លីដែលបានប៉ាន់ស្មាន**

**ទំនាក់ទំនងរយៈពេលវែង :**

(3.1a) $\pi_t^{CAM_Headline} = -1.66 + 1.09\pi_t^{INT_Headline} + 0.16M1_t * D1_t$; $R^2 = 0.96$

(-2.87) (11.13) (6.01) t-statistic

(3.1b) $\pi_t^{CAM_Food} = -1.08 + 1.07\pi_t^{INT_Food} + 0.42D1_t * \pi_t^{INT_Food}$; $R^2 = 0.92$

(-2.17) (13.67) (5.37) t-statistic

(3.1.c) $\pi_t^{CAM_Core} = 0.13 + 0.079M1_t + 0.076M1_t * D1_t$; $R^2 = 0.77$

(0.27) (3.14) (5.58) t-statistic

**ទំនាក់ទំនងរយៈពេលខ្លី :**

(3.2a) $\Delta\pi_t^{CAM_Headline} = 0.46\Delta\pi_{t-1}^{CAM_Headline} + 0.49\Delta\pi_{t-1}^{INT_Headline} - 0.13(ECM_{t-1})$; $R^2 = 0.29$

(3.54) (2.78) (-2.28) t-statistic

(3.2a) $\Delta\pi_t^{CAM_Food} = 0.49\Delta\pi_{t-1}^{CAM_Food} + 0.72\Delta\pi_{t-1}^{INT_Food} - 0.18(ECM_{t-1})$; $R^2 = 0.36$

(4.13) (3.91) (-2.97) t-statistic

(3.2a) $\Delta\pi_t^{CAM_Core} = 0.07\Delta M1_{t-1} - 0.21(ECM_{t-1})$; $R^2 = 0.24$

(2.92) (-2.24) t-statistic

ប្រភព : ការគណនារបស់បុគ្គលិក ADB

២១. **អញ្ញត្តិកំណត់ (Determinant) រយៈពេលវែងនៃអតិផរណា :** សមីការបីដំបូងនៅក្នុងតារាងទី៣ បង្ហាញពីទំនាក់ទំនងក្នុងរយៈពេលវែង រវាងរង្វាស់អតិផរណាចំនួនបី (គឺអតិផរណារួម អតិផរណាម្ហូបអាហារ និងអតិផរណាគោល) នៅក្នុងប្រទេសកម្ពុជា និងអថេរដែលពន្យល់នៅក្នុងសមីការទាំងនោះ ។ លទ្ធផលនោះបានបង្ហាញឱ្យឃើញថា :

I. **អតិផរណារបស់ដៃគូពាណិជ្ជកម្ម គឺជាអថេរដ៏សំខាន់បំផុតសម្រាប់ពន្យល់ពីបម្រែបម្រួលនៃអតិផរណានៅក្នុងប្រទេសកម្ពុជា។** នេះគឺជាការពិតចំពោះអតិផរណារួម និងអតិផរណាម្ហូបអាហារ (សមីការ ៣.១.ក និង ៣.១.ខ) ។ អន្តរកម្មរវាងអតិផរណាថ្លៃម្ហូបអាហាររបស់ដៃគូពាណិជ្ជកម្ម និងអថេរមិនពិត (D1) ក៏ត្រូវបានគេរកឃើញថា មានសារៈសំខាន់ខ្លាំងណាស់ដែរ ចំពោះសមីការថ្លៃម្ហូបអាហារ (៣.១.ខ) ដែលជាការបញ្ជាក់ពីកម្រិតគម្លាតនៃអតិផរណាម្ហូបអាហារក្នុងស្រុកចាប់តាំងពីដើមឆ្នាំ ២០០៧ ។

II. **បរិមាណសាច់ប្រាក់ និងអន្តរកម្មរបស់វាជាមួយអថេរមិនពិត មានសារៈសំខាន់នៅក្នុងការពន្យល់ពីអតិផរណាគោល។** លទ្ធផលនេះបានបង្ហាញថា សាច់ប្រាក់ (M1) ពិតជាមានតួនាទីសារៈសំខាន់លើអតិផរណាក្នុងស្រុក តាមរយៈតម្លៃនៃមុខ ទំនិញដែលមិនអាចធ្វើពាណិជ្ជកម្មបាននៅលើទីផ្សារ ហើយវាក៏បានជះឥទ្ធិពលកាន់តែខ្លាំង ចាប់តាំងពីចុងឆ្នាំ២០០៧ មក នៅពេលដែលសេដ្ឋកិច្ចបានបង្ហាញសញ្ញាកើនល្បឿនជ្រុលពេក (សមីការ៣.១.គ)។ ក៏ប៉ុន្តែ ទំហំនៃអថេរបរិមាណផ្គត់ផ្គង់ រូបិយវត្ថុ មានកម្រិតសមល្មមមុនឆ្នាំ ២០០៧។ មុនឆ្នាំ ២០០៧ អថេរនេះ មានមេគុណ 0.0៧ មានន័យថា ការកើនឡើង ១០% ក្នុងកំណើនរូបិយវត្ថុ (M1) បានបន្ថែមកំណើន 0.៧% ទៅលើអតិផរណាគោល។ នៅអំឡុងឆ្នាំ ២០០៧ ក្នុងពេលដែល សេដ្ឋកិច្ចកំពុងបង្ហាញសញ្ញាកើនល្បឿនជ្រុលពេក មេគុណបរិមាណសាច់ប្រាក់បានកើនឡើងទ្វេដង គឺដល់ទៅ 0.១៥៥ មានន័យថា ការកើនឡើង ១០% នៃបរិមាណសាច់ប្រាក់ (M1) ធ្វើឱ្យអតិផរណាកើនឡើងដល់ទៅ ១.៥៥%។ បរិមាណ សាច់ប្រាក់មិនជះឥទ្ធិពលដល់អតិផរណាថ្លៃម្ហូបអាហារទេ ព្រោះថា មុខទំនិញអាចធ្វើពាណិជ្ជកម្មបានរបស់ប្រទេសកម្ពុជា មានអន្តរកម្មជាមួយនិងប្រទេសជិតខាងធំៗរបស់ខ្លួន (សមីការ ៣.១.ក)។ បរិមាណសាច់ប្រាក់គឺមានផលប៉ះពាល់ទៅលើ តែអតិផរណារួម នៅពេលដែលវាអន្តរកម្មជាមួយនិងអថេរមិនពិត (សមីការ ៣.១.ក)។ ឥទ្ធិពលជាវិជ្ជមាននៃបរិមាណសាច់ប្រាក់ទៅលើអតិផរណារួមនេះ គឺបណ្តាលមកពីឥទ្ធិពលជាវិជ្ជមាននៃរូបិយវត្ថុ តាមរយៈអតិផរណាគោល។

III. **អត្រាប្តូរប្រាក់ មិនមានផលប៉ះពាល់ បើមើលតាមស្ថិតិទៅលើអតិផរណារួមនិងអតិផរណាគោលទេ ហើយត្រូវបាន** ដកចេញពីសមីការទាំងអស់។ តំបូង ការមិនមានផលប៉ះពាល់នេះ ទំនងជាគួរឱ្យភ្ញាក់ផ្អើលដែរ នៅពេលដែលអត្រាប្តូរប្រាក់ មិនមានផលប៉ះពាល់ទៅលើអត្រាអតិផរណារបស់ប្រទេសកម្ពុជា។ យើងអាចនិយាយបានថា ប្រហែលជាឥទ្ធិពលរបស់វា មានបង្កប់នៅក្នុងអត្រាអតិផរណានៃដៃគូពាណិជ្ជកម្មរបស់ខ្លួនរួចទៅហើយ។ ការរកឃើញដែលថា ទំនាក់ទំនងអត្រាប្តូរប្រាក់ *(ទៅនឹងថ្លៃទំនិញក្នុងស្រុក)* មានចំនួនតិចតួចសម្រាប់ប្រទេសកម្ពុជានោះ គឺវាមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងលទ្ធផលដែលគេទើបតែបានរកឃើញនៅក្នុងប្រទេសផ្សេងៗទៀត ដែលបានចូលរួមនៅក្នុងការរៀបចំឱ្យមានរូបិយប័ណ្ណរួម ដូចជាសហព័ន្ធរូបិយប័ណ្ណ (មានសហភាពអឺរ៉ុប) និងក្រុមប្រឹក្សារូបិយប័ណ្ណជាដើម។ ជាក់ស្តែង ការសិក្សាស្រាវជ្រាវផ្អែកលើទិន្នន័យតួលេខនាពេលថ្មីៗនេះមួយចំនួន បានបង្ហាញថា ឥទ្ធិពលពីអត្រាប្តូរប្រាក់ អាចនឹងធ្លាក់ចុះវិញនៅក្នុងប្រទេសទាំងឡាយណាដែលរួមគ្នារៀបចំឱ្យមានរូបិយប័ណ្ណរួម។ ភាគច្រើន ការកាត់បន្ថយឥទ្ធិពលដែលបានប្រយោជន៍ដល់អ្នកប្រើប្រាស់ដែលស្ថិតក្រោមកិច្ចរៀបចំឱ្យមានរូបិយប័ណ្ណរួម កើតមាននៅចន្លោះនៃការដាក់តម្លៃរវាងពីអ្នកទល់ដែន និងអ្នកលក់រាយ (Slavov 2008)។

២២. **ផលប៉ះពាល់ដែលមានរយៈពេលខ្លី** :លទ្ធផលប៉ាន់ស្មានលើម៉ូដែលអតិផរណារយៈពេលខ្លី សម្រាប់រង្វាស់អតិផរណាទាំងបី

មានបង្ហាញនៅខាងក្រោមក្នុងតារាង ៣ (សមីការ ៣.២.ក ដល់សមីការ ៣.២.គ) ។ ប្រព័ន្ធគណនា ត្រូវបានគេប៉ាន់ជាលើកដំបូងបំផុតដោយមានបញ្ចូលនូវអញ្ញត្តិក្រាមុនខ្លះ៧ដោយយកថយឆ្នាំ ប៉ុន្តែរក្សាទុកតែអថេរ ដែលមានតួលេខសំខាន់៧ប៉ុណ្ណោះ ។ អថេរមិនពិត និងអន្តរកម្មទាំងឡាយ ត្រូវបានដកចេញពីប្រព័ន្ធគណនានេះ ។ លទ្ធផលទាំងនេះបានបង្ហាញឱ្យដឹងថា :

I. **អតិផរណាមួយចំនួនគឺនៅតែមាន ។** អថេរចំណុះគេដែលយកថយឆ្នាំ បានស្តែងចេញជាតួលេខស្ថិតិយ៉ាងសំខាន់នៅក្នុងសមីការអតិផរណាម្ហូបអាហារនិងអតិផរណារួម ជាការចង្អុលឱ្យឃើញថាអតិផរណាមួយចំនួននៅតែមាន ។ ប៉ុន្តែមេគុណអថេរចំណុះគេនេះ មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការការពារមិនឱ្យមានការប្រសព្វគ្នារវាងអតិផរណាទៅនឹងតួលេខក្នុងរយៈពេលវែងរបស់វាបានឡើយ ។

II. **អតិផរណារបស់ដៃគូពាណិជ្ជកម្មជះឥទ្ធិពលទៅលើអតិផរណារួម និងអតិផរណាម្ហូបអាហារនៅក្នុងរយៈពេលខ្លី ។** មេគុណរបស់អតិផរណានេះ ជាមេគុណធំនៅក្នុងសមីការសម្រាប់អតិផរណាម្ហូបអាហារ សឱ្យឃើញថា អតិផរណា របស់ដៃគូពាណិជ្ជកម្ម ដើរតួយ៉ាងសំខាន់នៅក្នុងការបង្កឱ្យមានចលករនៃអតិផរណាម្ហូបអាហារ គឺសំខាន់ជាងនៅក្នុងអតិផរណារួមនៅក្នុងប្រទេសកម្ពុជា ។

III. **មេគុណនៅក្នុងអញ្ញត្តិកែតម្រូវកំហុសសម្រាប់អតិផរណារួម និងអតិផរណាម្ហូបអាហារគឺ ០,១៣ និង ០.១៨ រៀងគ្នា ដែលសឱ្យឃើញនូវរយៈពេលកែសម្រួលមួយដែលរហ័សល្មម ។** មេគុណសម្រាប់អតិផរណាម្ហូបអាហារនេះធំជាងមេគុណអតិផរណារួមប្រហែលជា ៥០% ។ នេះមានន័យថា ការកែសម្រួលសម្រាប់អតិផរណាម្ហូបអាហារនៅពេលដែលវាដើរលែងស្របគ្នាទៅនឹងការកែសម្រួលអតិផរណារបស់ដៃគូពាណិជ្ជកម្មនានា កើតឡើងលឿនជាងការកែសម្រួលសម្រាប់អតិផរណារួម ។ មេគុណ ០,១៨ គឺមានន័យថា ដំណើរការជួបប្រសព្វគ្នាវិញ (ពាក់កណ្តាលវដ្ត) អាចបញ្ចប់ក្នុងរយៈពេល ពីពីរទៅបីខែ ។ ការកែសម្រួលរហ័សល្មមសម្រាប់អតិផរណាម្ហូបអាហារនេះ ស្តែងឱ្យឃើញពីផលិតផលទីផ្សារដែលមានលក្ខណៈបត់បែន និងសមាហរណគ្នាទៅវិញទៅមក សម្រាប់មុខទំនិញដែលធ្វើពាណិជ្ជកម្មបាន ។

IV. **សាច់ប្រាក់ គឺជាអថេរមួយយ៉ាងសំខាន់ ដែលពន្យល់ពីកំលាំងចលកររយៈពេលខ្លីនៃអតិផរណាគោល ។** គេបានធ្វើតេស្តដោយយកអថេរថយឆ្នាំបន្តបន្ទាប់គ្នារហូតដល់ទៅ ១២ខែ មកប្រើប្រាស់ក្នុងសមីការដូចគ្នា ប៉ុន្តែគេបានរកឃើញថាមាន តែអថេរថយឆ្នាំគ្រាបន្ទាប់គេប៉ុណ្ណោះ ដែលមានតួលេខសំខាន់ ។ ក្នុងខណៈដែលចំនួនគ្រាថយឆ្នាំនេះខ្លីបន្តិច ការណ៍នេះប្រហែលជាអាចឆ្លុះបញ្ចាំងពីលក្ខណៈពិសេសនៃសេដ្ឋកិច្ច ដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើសាច់ប្រាក់ ។

## IV. ទំនាក់ទំនងគោលនយោបាយ និងការប្រឈមនាពេលអនាគត

២៣. លទ្ធផលនៃរបាយការណ៍នេះ បង្ហាញពីការការសន្និដ្ឋានទៅលើគោលនយោបាយមួយចំនួនទាំងក្នុងរយៈពេលខ្លី និងក្នុងរយៈពេលវែងជាងនេះ ។ របាយការណ៍នេះ សង្ខេបនូវសេចក្តីសន្និដ្ឋានទាំងនោះ ហើយផ្តល់ជាយោបល់មួយចំនួន ដើម្បីលើកកម្ពស់ក្របខ័ណ្ឌ និងវិធានការសំរាប់កាត់បន្ថយឥទ្ធិពលនៃការឡើងគំហុកនៃតម្លៃទៅលើប្រជាពលរដ្ឋក្រីក្រ ។

២៤. សម្រាប់រយៈពេលខ្លី

- **ការប្រែប្រួលតម្លៃម្ហូបអាហារនៅក្នុងប្រទេសកម្ពុជា ដែលបង្ហាញឱ្យឃើញនូវបម្រែបម្រួលដ៏ធំនៃតួលេខអតិផរណារួមមានលក្ខណៈផ្សារភ្ជាប់ទៅនឹងដំណើរការជាអន្តរជាតិតាមរយៈដៃគូពាណិជ្ជកម្មនានារបស់ខ្លួន ។** ការចំណាយទៅលើការប្រើប្រាស់ថាមពល និងការដឹកជញ្ជូន ក៏បានរួមចំណែកដល់កំណើនអតិផរណាក្នុងពេលថ្មីៗនេះផងដែរ ។ បញ្ហានេះ កើតឡើងដោយសារតែតម្លៃប្រេងនៅកម្ពុជាប្រែប្រួលទៅតាមតម្លៃប្រេងអន្តរជាតិ ។ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៅក្នុងប្រទេសមានតួនាទីតិចតួច ក្នុងការជះឥទ្ធិពលទៅលើប្រភពសម្ពាធអតិផរណានេះសម្រាប់រយៈពេលវែង ។

- **អតិផរណាគោល ដោយមិនរាប់បញ្ចូលម្ហូបអហារ ថាមពល និងការដឹកជញ្ជូន គឺជារង្វាស់ដ៏ប្រសើរសម្រាប់អតិផរណាមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា ហើយគួរត្រូវបានគេសង្កេតនិងតាមដានឱ្យបានល្អិតល្អន់ ។** អតិផរណាគោល បានកើនឡើងចាប់តាំងពីចុងឆ្នាំ២០០៧ មក ។ កំណើនអតិផរណានេះ គឺជាការបង្ហាញឱ្យឃើញនូវឥទ្ធិពលជុំទីពីរ នៃអតិផរណាតម្លៃអន្តរជាតិធៀបនឹងតម្លៃទំនិញក្នុងស្រុកដែលមិនសម្រាប់ធ្វើពាណិជ្ជកម្ម ។ ទន្ទឹមនឹងនេះ គេដឹងយ៉ាងច្បាស់ថា សេដ្ឋកិច្ចកំពុងតែកើនលឿនជ្រុលពេក ដែលប្រហែលជាបានធ្វើឱ្យមានផលមិនល្អ ដល់កំណើនអតិផរណាគោល ។

- **ឥទ្ធិពលនៃនយោបាយម៉ាក្រូសេដ្ឋកិច្ចក្នុងស្រុក (នយោបាយសារពើពន្ធ និងនយោបាយហិរញ្ញវត្ថុ) ទៅលើតម្លៃទំនិញក្នុងស្រុក គឺស្តែងចេញតាមរយៈតម្លៃទំនិញនិងសេវាកម្មនានាដែលមិនសម្រាប់ធ្វើពាណិជ្ជកម្ម។** ការស្តែងចេញនេះនឹងត្រូវបានគេមើលឃើញនៅក្នុងអតិផរណាគោល ។ ដោយសារការសិក្សាស្រាវជ្រាវបានបង្ហាញថា កំណើនសាច់ប្រាក់ (M1) បានជះឥទ្ធិពលទៅលើការប្រែប្រួលអតិផរណាគោលនៅកម្ពុជា គោលនយោបាយរូបិយវត្ថុ អាចរួមចំណែកនៅក្នុងការកាត់បន្ថយអតិផរណាក្នុងស្រុកតាមរយៈតម្លៃទំនិញ និងសេវាកម្មនានា ដែលមិនសម្រាប់ធ្វើពាណិជ្ជកម្ម។ ដូច្នេះ ការរកឃើញនេះបានផ្តល់ការគាំទ្រដល់ចំណាត់ការរបស់ធនាគារជាតិនៃកម្ពុជាពេលថ្មីៗកន្លងទៅ ក្នុងការរឹតបណ្តឹងនយោបាយរូបិយវត្ថុតាមរយៈការបង្កើនតម្រូវការទុនបម្រុង កាត់បន្ថយកុំឱ្យធានាគារពាណិជ្ជផ្តល់កម្ចីច្រើនជ្រុលដល់វិស័យអចលនទ្រព្យ និងបន្ធូរបន្ថយការគ្រប់គ្រងដើមទុនជាបណ្តោះអាសន្ន ដើម្បីឱ្យធនាគារអាចយកសាច់ប្រាក់ងាយស្រួលដែលលើសសេសសល់ទៅដាក់នៅក្រៅប្រទេសយកកំរៃ ។ ប្រសិនបើនៅតែមានអតិផរណាតម្លៃម្ហូបអាហារដែលជំរុញដោយបញ្ហាផ្គត់ផ្គង់ដូចពេលបច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាគួរតែបន្តមានចំណាត់ការដើម្បីកាត់បន្ថយឥទ្ធិពលនៅជុំទីពីរ ។ នៅក្នុងករណីនេះ ជម្រើសវិធានការ គឺដូចគ្នាជាដដែល ។ អតិផរណាតម្លៃម្ហូបអាហារមិនថមថយ អាចជំរុញឱ្យបៀវត្សរ៍មានការកើនឡើង ហើយ

ឡើងជ្រុលអាចនាំឱ្យមានសម្ពាធអតិផរណាបន្ថែម ឬនាំឱ្យមានបាតុភូតរង្វិលជុំនៃប្រៀវត្សរ៍និងថ្លៃប្រដេញគ្នាទៅវិញ ទៅមក ។ នៅពេលធ្វើការពិចារណាលើជម្រើសគោលនយោបាយ គេគួរតាមដានអត្រាកំណើននៃប្រាក់បៀវត្សរ៍ ។

- **នយោបាយសារពើពន្ធ គឺជាគន្លឹះគោលនយោបាយមួយយ៉ាងសំខាន់សម្រាប់គ្រប់គ្រងអតិផរណា ។** ដោយសារថា ជម្រើសគោលនយោបាយរូបិយវត្ថុមានកំណត់ រដ្ឋាភិបាលត្រូវពិចារណាលើជម្រើសនយោបាយសារពើពន្ធផងដែរនៅពេលណាដែលផលប៉ះពាល់ជុំទីពីរកើតឡើង ឬប្រសិនបើមានសញ្ញាបង្ហាញថា សេដ្ឋកិច្ចកំពុងកើនល្បឿនជ្រុលពេក ដូចកាលពីឆ្នាំ២០០៧ ។ រដ្ឋាភិបាលសម្រេចបាននូវអតិរេកសាច់ប្រាក់នៅឆ្នាំ២០០៧ និង ២០០៨ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងប្រាក់បញ្ញើដែលបានបង្គរទុកក្នុងប្រព័ន្ធធនាគារ ។ ជំហរគោលនយោបាយនេះមានលក្ខណៈសមស្រប ត្បិតថាបើនិយាយទៅរដ្ឋាភិបាល គួរតែមានជំហរនយោបាយសារពើពន្ធមួយម៉ឹងម៉ាត់ជាងនេះក្នុងការទ្រទ្រង់សេដ្ឋកិច្ច នៅពេលដែលការផ្តល់ឥណទានដល់វិស័យ ឯកជនបានកើនហួសកម្រិតកាលពីឆ្នាំ ២០០៧ ។ ក្រោមរបបអត្រាប្តូរប្រាក់បច្ចុប្បន្ននេះ ចំណាត់ការសារពើពន្ធបែបនេះ នឹងមានប្រសិទ្ធភាពជាងចំណាត់ការខាងនយោបាយហិរញ្ញវត្ថុផងដែរ ក្នុងការកាត់បន្ថយសម្ពាធអតិផរណាដែលបណ្តាលមក ពីតម្រូវការកើនឡើង ។
- បច្ចុប្បន្ននេះ ចរាចរទំនិញមិនសម្រាប់ពាណិជ្ជកម្មនៅក្នុង PP-RPI ត្រូវបានគ្របដណ្តប់លើសលប់ដោយតម្លៃជួលផ្ទះ ដោយសារតែវាមានមធ្យមទម្ងន់ធំ ។ រង្វាស់ចលនាថ្លៃទំនិញមិនសម្រាប់ធ្វើពាណិជ្ជកម្មដែលមានលក្ខណៈប្រសើរជាងនេះ នឹងជួយពង្រឹងរង្វាស់អតិផរណាគោលបានល្អប្រសើរឡើង ហើយក៏នឹងជួយបង្កើតគោលនយោបាយក្នុងស្រុក ដើម្បីគ្រប់គ្រងអតិផរណាបានទៀតផង ។

សម្រាប់រយៈពេលវែង

២៥. ជាការចាំបាច់នោះ គឺត្រូវពង្រឹងប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ ដើម្បីគ្រប់គ្រងអតិផរណាក្នុងស្រុក ។ ធនាគារជាតិនៃកម្ពុជា ត្រូវបង្កើនវិធានការរបស់ខ្លួន បន្ថែមពីលើវិធានការអត្រាតម្រូវការទុនបម្រុង និងវិធានការរដ្ឋបាលផ្សេងៗទៀត ។ ខាងក្រោមនេះ គឺជាគោលការណ៍ទូទៅមួយចំនួន ដែលរដ្ឋាភិបាលចាំបាច់គួរពិចារណា ប្រសិនបើខ្លួនសម្រេចចិត្តថានឹងបង្កើនតួនាទីគោលនយោបាយរូបិយវត្ថុ និងវិធានការនានា ដោយទទួលស្គាល់ថា នេះគឺជាកិច្ចខិតខំប្រឹងប្រែងសម្រាប់រយៈពេលវែង ។

២៦. **ធនាគារកណ្តាលនៅក្នុងប្រទេសកំពុងលេចធ្លោ បានបង្កើនការពឹងផ្អែករបស់ខ្លួនទៅលើប្រតិបត្តិការទីផ្សាររូបិយវត្ថុក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ខណៈដែលវិស័យហិរញ្ញវត្ថុរបស់ខ្លួនកាន់តែមានការអភិវឌ្ឍទៅមុខ ។** បទពិសោធន៍ជាអន្តរជាតិមួយបានបង្ហាញឱ្យដឹងថា របត់ឈានទៅរកការប្រើប្រាស់ឧបករណ៍នៃទីផ្សាររូបិយវត្ថុក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ចាំបាច់ត្រូវបំពេញឱ្យបាននូវលក្ខខណ្ឌចំនួនបី :

១. បន្តនយោបាយសារពើពន្ធមួយយ៉ាងរឹងមាំ
២. មានប្រព័ន្ធហិរញ្ញវត្ថុល្អ និងមានលក្ខណៈប្រកួតប្រជែង ដែលមានក្របខ័ណ្ឌត្រួតពិនិត្យគ្រប់គ្រាន់ និង
៣. មានសមត្ថភាពធ្វើការ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់លើស្វ័យភាពរបស់ស្ថាប័នធនាគារកណ្តាល

២៧. **វិន័យខាងថវិកា:** ការបន្តមានវិន័យខាងថវិកា គឺជាគន្លឹះឆ្ពោះទៅរកការបង្កើនប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ ពីព្រោះការខ្វះវិន័យ តែងតែធ្វើឱ្យបន្ទុចបង្អាក់ដល់ការអភិវឌ្ឍទីផ្សារមូលប័ត្ររបស់រដ្ឋាភិបាល ដែលជាប្រការចាំបាច់សម្រាប់ប្រតិបត្តិការរូបិយវត្ថុ ហើយក៏កាត់បន្ថយឥទ្ធិពលធនាគារកណ្ដាលទៅលើស្ថានភាពសាច់ប្រាក់ងាយស្រួលដែរ ក៏ដូចជាធ្វើឱ្យមានតម្រូវការលើស និងមានអតិផរណាផងដែរ ។ នៅក្នុងសេដ្ឋកិច្ចដែលស្ថិតនៅដំណាក់កាលដំបូងនៃការរីកចម្រើនផ្នែកហិរញ្ញវត្ថុ ធនាគារកណ្ដាល ប្រហែលជាមិនអាចស្រូបយកសាច់ប្រាក់ងាយស្រួលដែលនៅលើសសេសសល់ដែលបណ្ដាលមកពីអតុល្យភាពសារពើពន្ធបានទេ ព្រោះថា ជម្រើសដើម្បីរៀបចំប្រតិបត្តិការរូបិយវត្ថុមានកំណត់ ។

២៨. **កំណែទម្រង់វិស័យហិរញ្ញវត្ថុ:** វិធានការនានា ដែលធ្វើឱ្យប្រព័ន្ធហិរញ្ញវត្ថុកាន់តែមានភាពស៊ីជម្រៅ ត្រូវបន្តអនុវត្តឱ្យឈានដល់មួយកម្រិតទៀត ។ កម្រិតនៃប្រតិបត្តិការទីផ្សាររូបិយវត្ថុអាចពេញលេញទៅបាន លុះត្រាតែមុខងារផ្ដល់ឥណទានរបស់ធនាគារពាណិជ្ជមានការវិវត្តរីកចម្រើនឡើង ។ នៅពេលដែលមុខងារផ្ដល់ឥណទានរបស់ធនាគារមានការរីកចំរើន ទីផ្សារអន្តរធនាគារក៏ត្រូវតែមានការរីកចំរើនដែរហើយ ។ នៅពេលទីផ្សារអន្តរធនាគារកាន់តែមានភាពស៊ីជម្រៅ ធនាគារជាតិនៃកម្ពុជាអាចងាកពីវិធានការដែលនៅមានសេសសល់ប៉ុន្មានដែលអាស្រ័យតាមវិធានច្បាប់ជាមួយដ្ឋានមកជាប្រតិបត្តិការទីផ្សាររូបិយវត្ថុវិញ ។ មានកត្តាមួយចំនួនដែលអាចធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍទីផ្សារអន្តរធនាគារ រួមទាំងស្ថានភាពហិរញ្ញវត្ថុទន់ខ្សោយរបស់អ្នកចូលរួម ការបែងចែកទីផ្សារ និងបញ្ហាមានសាច់ប្រាក់ងាយស្រួលលើសលប់ដែលកើតមានជាយូរមកហើយ ដែលពាក់ព័ន្ធទៅនឹងការខ្វះវិន័យខាងថវិកា ឬបញ្ហាផ្សេងៗទៀតដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធគ្រឹះនៃសេដ្ឋកិច្ច ។

២៩. **សមត្ថភាពស្ថាប័ន :** ការពង្រឹងសមត្ថភាពប្រតិបត្តិការ និងស្វ័យភាពគ្រប់គ្រាន់នៃផ្នែកស្ថាប័នរបស់ធនាគារកណ្ដាល នឹងជួយបង្កើននូវទំនុកចិត្ត និងប្រសិទ្ធភាពគោលនយោបាយហិរញ្ញវត្ថុ ។ កត្តានេះ នឹងបង្កើតឱ្យមានគោលដៅតែមួយនិងច្បាស់លាស់ សម្រាប់ធនាគារកណ្ដាល ក៏ដូចជាធ្វើឱ្យមានតុល្យភាពមួយសមស្របរវាងនយោបាយរូបិយវត្ថុ និងនយោបាយសារពើពន្ធ នៅក្នុងដំណើរការបង្កើតគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ។

៣០. **ផែនការសកម្មភាពរយៈពេលមធ្យម:** ដើម្បីបង្កើតឱ្យមាននូវលក្ខខណ្ឌជាអាទិភាពទាំងបីនេះសម្រាប់រយៈពេលវែង ការសិក្សានេះ បានជូនជាយោបល់ថា ធនាគារជាតិនៃកម្ពុជាគួរធ្វើការវាយតម្លៃទៅលើហេដ្ឋារចនាសម្ព័ន្ធទីផ្សារដែលមានស្រាប់ អភិវឌ្ឍផែនការសម្មភាព ដើម្បីពង្រឹងចំណុចខ្សោយដែលមាន និងកែសម្រួលល្បាយនៃវិធានគោលនយោបាយរូបិយវត្ថុ នៅពេលការអនុវត្តមានវឌ្ឍនភាព ។ នៅក្នុងបរិបទនេះ អត្ថបទសិក្សានេះ ជូនជាយោបល់ថា ធនាគារជាតិនៃកម្ពុជា គួរតែបង្កើតផែនការសកម្មភាពរយៈពេលមធ្យម ដើម្បីលើកកម្ពស់ល្បាយនៃវិធានគ្រប់គ្រងរូបិយវត្ថុចម្រុះរបស់ខ្លួន ដែលគួរត្រូវរាប់បញ្ចូលទាំងសកម្មភាពជំរុញឱ្យមានការបង្កើតទីផ្សារអន្តរធនាគារផងដែរ ។ បញ្ហាសំខាន់ៗដែលត្រូវយកចិត្តទុកដាក់សម្រាប់រយៈពេលវែងរួមមាន : (១) រៀបចំឱ្យមានវិធានផ្អែកលើទីផ្សារមួយចំនួន ដូចជា កិច្ចសន្យាទិញទុក-លក់ ទៅវិញទៅមក ជាមួយធនាគារ និងមុខងារប័ណ្ណរតនាគារ

និងឥទ្ធិពលប៉ះពាល់លើថវិការបស់វា (២) ជម្រើសរូបិយប័ណ្ណ ដែលអាចប្រើប្រាស់បានលើសលប់នៅក្នុងឧបករណ៍ទីផ្សារ (៣) ចំណោត់ការសម្រាប់អភិវឌ្ឍសមត្ថភាពនៅក្នុងការរៀបចំប្រតិបត្តិការលក់ដូរមូលប័ត្រក្នុងទីផ្សារបើកទូលាយ ។

**ការកាត់បន្ថយឥទ្ធិពលនានាទៅលើអ្នកក្រីក្រ និងគ្រួសារដែលងាយរងគ្រោះ**

៣១. **គោលនយោបាយសារពើពន្ធ :** រដ្ឋាភិបាលអាចប្រើប្រាស់គោលនយោបាយសារពើពន្ធ ដើម្បីផ្តល់ជំនួយសង្គ្រោះបណ្តោះអាសន្នដល់គ្រួសារក្រីក្រ ដែលរងផលប៉ះពាល់ដោយសារបញ្ហាខាងការផ្គត់ផ្គង់ ។ នៅក្នុងការរៀបចំវិធានការសង្គ្រោះនេះ បទពិសោធន៍ដែលទទួលបានពីប្រទេសផ្សេងៗទៀត បានបង្ហាញជាគំនិតយោបល់ដូចតទៅ :

- ការអនុគ្រោះពន្ធប្រយោល ដូចជា ការមិនយកពន្ធលើតម្លៃបន្ថែម ឬពន្ធផ្សេងៗទៀតនោះលើម្ហូបអាហារ គឺជាវិធានការដោះស្រាយមួយ ដែលកម្រនឹងសម្រេចគោលដៅណាស់ ។ នៅពេលដែលការរួចពន្ធត្រូវបានផ្តល់ឱ្យហើយ វានឹងផ្តល់ផលលំបាកផ្នែកនយោបាយ នៅពេលគេចង់លុបបំបាត់ទៅវិញក្នុងពេលអានាគត ។ ដោយសារថា អត្រាបង់ពន្ធធៀបនឹងផលិតផលក្នុងស្រុកសរុបនៅក្នុងប្រទេសកម្ពុជាមានកម្រិតទាប (ជាសេដ្ឋកិច្ចមានចំណូលពន្ធទាប) វិធានការអនុគ្រោះពន្ធមិនគួរយកមកអនុវត្តទេ ។

- ការហាមឃាត់ការនាំចេញ ឬពន្ធនាំចេញលើទំនិញផ្សេងៗ ដូចជាម្ហូបអាហារ ក្នុងគោលបំណងធ្វើឱ្យមានការចែករំលែកផលប្រយោជន៍ពីកសិករទៅអតិថិជន មិនគួរយកមកអនុវត្តឡើយ ព្រោះថាការដាក់កំហិតបែបនេះ នឹងធ្វើឱ្យប៉ះពាល់ដល់ការផ្គត់ផ្គង់ក្នុងស្រុកសម្រាប់រយៈពេលវែង ។

- ឧបត្ថម្ភធនដើម្បីបន្ថយតម្លៃម្ហូបអាហារ គឺជាជំនួយ ដែលកម្រនឹងអាចឆ្ពោះទៅដល់គោលដៅណាស់ ហើយត្រូវចំណាយថវិកាច្រើន ដោយសារនៅក្នុងការឧបត្ថម្ភបែបនេះ ប្រព័ន្ធចែកចាយច្រើនតែមានលក្ខណៈទន់ខ្សោយ ។ វិធានការបែបនេះមិនគួរយកមកអនុវត្តទេ លើកលែងតែស្ថិតក្នុងស្ថានភាពខ្វះស្បៀងអាហារដែលត្រូវសង្គ្រោះបន្ទាន់ ។

- កម្មវិធីផ្តល់ជំនួយសង្គមដោយផ្ទាល់ និយាយជារួមការផ្តល់សាច់ប្រាក់សុទ្ធតែម្តង ច្រើនមានប្រសិទ្ធភាពជាង ហើយទៅដល់ក្រុមគោលដៅ និងជាទូទៅចំណាយថវិកាតិចតួចប៉ុណ្ណោះក្នុងការអនុវត្ត ។ ការផ្តល់ជាសាច់ប្រាក់ អាចអនុវត្តបានលឿនជាង ។ រដ្ឋាភិបាលឥណ្ឌូនេស៊ី បានអនុវត្តកម្មវិធីផ្តល់ប្រាក់ដោយគ្មានលក្ខខណ្ឌជាបណ្តោះអាសន្នមួយ ដើម្បីជាការប៉ះប៉ូវដល់គ្រួសារនានា ក្នុងខណៈដែលប្រេងឡើងថ្លៃកាលពីខែតុលា ឆ្នាំ២០០៥ ។ រដ្ឋាភិបាល ត្រូវចំណាយពេលពីបីទៅប្រាំមួយខែ ដើម្បីរៀបចំ និងបើកប្រាក់ជាលើកដំបូងទៅឱ្យគ្រួសារដែលត្រូវទទួលរបប ។ រដ្ឋាភិបាលចាប់ផ្តើមដំណើរការផ្តល់សាច់ប្រាក់ដោយឥតលក្ខខណ្ឌ (UCT) ឡើងវិញនៅពាក់កណ្តាលឆ្នាំ២០០៨ ដើម្បីជាការឆ្លើយតបទៅនឹងការកើនឡើងនៃតម្លៃទំនិញ និងអតិផរណាក្នុងស្រុក ។ កម្មវិធី UCT សំដៅជួយដល់ ១៩ លានគ្រួសារ ដោយផ្អែកលើមូលដ្ឋានទិន្នន័យដែលគេប្រើប្រាស់នៅក្នុង UCT កាលពីមុន ក្នុងឆ្នាំ២០០៥ និង ២០០៦ ។ គ្រួសារនីមួយៗ ត្រូវទទួលបានប្រាក់ ១០ដុល្លារ ក្នុងមួយខែ

ហើយបើករាល់បីខែម្តង។ ទិន្នន័យជាលើកដំបូងស្តីពីប្រសិទ្ធភាពនៃការកាត់បន្ថយភាពក្រីក្ររបស់ UCT ស្តែងចេញជាលទ្ធផលគួរជាទីលើកទឹកចិត្ត។ យោងទៅតាមទិន្នន័យ ដែលបានមកពីការអង្កេតសង្គមកិច្ចនិងសេដ្ឋកិច្ចទៅលើគ្រួសារឥណ្ឌូនេស៊ី កាលពីឆ្នាំ ២០០៨ UCT រក្សាបាននូវកម្រិតសុខមាលភាពចំនួន ៦០% នៃគ្រួសារដែលជាអ្នកទទួលបានការឧបត្ថម្ភពី UCT ហើយជួយដល់គ្រួសារចំនួន ៣០% ទៀតឱ្យរួចផុតពីភាពក្រីក្រ រីឯ ១០% នៃគ្រួសារផ្សេងទៀតបានធ្លាក់ចូលទៅក្នុងភាពក្រីក្រ ដោយសារតែអតិផរណាតម្លៃម្ហូបអាហារក្នុងឆ្នាំ ២០០៨។

៣២. **កម្មវិធីផ្តល់ប្រាក់ដោយមានលក្ខខណ្ឌ (CCT) ក៏ជាមធ្យោបាយមួយដ៏មានប្រសិទ្ធភាពដែរ ដើម្បីជាការប៉ះប៉ូវដល់គ្រួសារទាំងឡាយ ហើយទន្ទឹមនឹងនេះ ក៏ជាការកសាងធនធានមនុស្សនៅក្នុងគ្រួសារក្រីក្រដែរ**។ កម្មវិធី CCT ដូចគ្នាទៅនឹងកម្មវិធី UCT ដែរ គ្រាន់តែកម្មវិធីនេះ ផ្តល់ជំនួយហិរញ្ញវត្ថុទៅឱ្យគ្រួសារនានា ក្រោមលក្ខខណ្ឌមួយចំនួនពិតប្រាកដ ដែលត្រូវផ្សារភ្ជាប់ទៅនឹងការបណ្តុះសមត្ថភាពកុមារ ដូចជាលទ្ធផលការសិក្សា និងសុខភាពជាដើម។ តាមពិត កម្មវិធីនេះផ្តល់ការលើកទឹកចិត្តដល់គ្រួសារទាំងឡាយឱ្យចេះកែប្រែឥរិយាបទ ដូចជាការយកកូនទៅចុះឈ្មោះចូលរៀន និងឱ្យពួកគេទៅរៀនបានទៀងទាត់ ឬត្រូវតាមដានការចាក់ថ្នាំបង្ការដល់កុមារជានិច្ច ។ល។ បង្កើត CCT ត្រូវបានចំណាយពេលច្រើន ប្រសិនបើសមត្ថភាពស្ថាប័នដែលត្រូវផ្តល់ជូនទៅឱ្យកម្មវិធីនេះនៅមានភាពទន់ខ្សោយ។ កម្មវិធីនេះទាមទារឱ្យមាននូវប្រព័ន្ធតាមដានមានប្រសិទ្ធភាពនិងត្រូវចាយពេលវេលាច្រើន ព្រមទាំងត្រូវមានអ្នកជួយសម្របសម្រួលផងដែរ។ កម្មវិធីនេះ ក៏តម្រូវឱ្យមានវិធីសាស្ត្រដៅកំណត់គ្រួសារក្រីក្រឱ្យបានត្រឹមត្រូវផងដែរ។ លើសពីនេះ ទៅទៀតកម្មវិធីនេះ ត្រូវការក្របខ័ណ្ឌអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។ ថ្មីៗនេះ ប្រទេសឥណ្ឌូនេស៊ីកំពុងធ្វើការ សាកល្បងលើកម្មវិធី CCT មួយ ជាមួយនិងក្រុមគ្រួសារ ដែលជាអ្នកទទួលប្រាក់ចំនួនប្រហែលជា ១លានគ្រួសារ។ គេត្រូវចំណាយពេលរៀបចំបរិយាកាសស្ថាប័នជាមុនសិន មុនពេលនឹងកម្មវិធីនេះ អាចយកមកអនុវត្តឱ្យមានប្រសិទ្ធភាពទូទាំងប្រទេស។

# ឧបសម្ព័ន្ធ ១

## តារាង ១.១ ប្រទេសកម្ពុជា : មុខទំនិញ និងទម្ងន់ នៅក្នុងតារាងសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ ២០០៣-២០០៨

| ល.រ | មុខទំនិញ | មធ្យម ទម្ងន់ | | មុខទំនិញ | មធ្យម ទម្ងន់ | | មុខទំនិញ | មធ្យម ទម្ងន់ |
|---|---|---|---|---|---|---|---|---|
| 001 | អង្ករលេខ ១ 1/ 2/ 3/ | 2.641 | 077 | ប៊ីចេង 1/ 2/ 3/ | 0.290 | 153 | ខ្មៅយ | 0.005 |
| 002 | អង្ករលេខ ២ 1/ 2/ 3/ | 4.058 | 078 | ទឹកស៊ីអ៊ីវ 1/ 2/ 3/ | 0.245 | 154 | ស្រោមខ្មៅយ | 0.004 |
| 003 | នំប៉័ង 1/ 2/ 3/ | 0.584 | 079 | ទឹកត្រី 1/ 2/ 3/ | 0.255 | 155 | កន្សែងពោះគោ | 0.006 |
| 004 | អង្ករដំណើប | 0.415 | 080 | ម្រេចហ្មត់ 1/ 2/ 3/ | 0.045 | 156 | ម៉ាស៊ីនភ្លើងម៉ាកយ៉ាម៉ាហា ៥០០ | 0.068 |
| 005 | អង្ករស 1/ 2/ 3/ | 0.280 | 081 | ខ្ទឹ 1/ 2/ 3/ | 0.030 | 157 | ទូទឹកកក ផលិតនៅប្រទេសថៃ | 0.019 |
| 006 | មី 1/2/3 | 0.610 | 082 | តែ 1/ 2/ 3/ | 0.461 | 158 | ម៉ាស៊ីនដេរ ផលិតនៅប្រទេសចិន | 0.009 |
| 007 | នំប៊ីសស្គីត 1/ 2/ 3/ | 0.061 | 083 | កាហ្វេ 1/ 2/ 3/ | 0.246 | 159 | កង្ហារប្រើភ្លើង ផលិតនៅប្រទេសថៃ | 0.017 |
| 008 | នំធ្វើពីអង្ករ | 0.197 | 084 | ទឹកកក 1/ 2/ 3/ | 0.725 | 160 | ឆ្នាំងអ៊ុត ( ថៃ) | 0.007 |
| 009 | សាច់សុទ្ធ ( ជ្រូក) 1/ 2/ 3/ | 2.401 | 085 | បាយ 1/ 2/ 3/ | 3.683 | 161 | កៅអី ( ថៃ) | 0.011 |
| 010 | សាច់ជ្រូកបីជាន់ 1/ 2/ 3/ | 1.331 | 086 | អាហារសម្រន់ 1/2/3 | 0.464 | 162 | ចានបាយ ( ថៃ) | 0.015 |
| 011 | សាច់គោ 1/ 2/ 3/ | 1.059 | 087 | អាហារឆ្អិនស្រាប់ 1/2/3 | 0.905 | 163 | ឆ្នាំងដាំបាយ (ខ្មែរ) | 0.000 |
| 012 | សាច់មាន់ 1/ 2/ 3/ | 2.004 | 088 | ផ្លែស្វាយកំប៉ុង | 0.511 | 164 | ប៉ាន់តែ | 0.002 |
| 013 | សាច់ 1/ 2/ 3/ | 0.285 | 089 | ទឹកផ្លែឈើ | 0.265 | 165 | កាំបិតតាំងតោ | 0.002 |
| 014 | មាន់ចៀន/ដុត 1/ 2/ 3/ | 0.228 | 090 | ស្រាបៀរអង្គរ | 0.321 | 166 | ខ្ទះឆា | 0.001 |
| 015 | ត្រីរស់ 1/ 2/ 3/ | 1.570 | 091 | ស្រាបៀរថៃហ្គ័រ | 0.749 | 167 | ចានគោម (ចិន) | 0.002 |
| 016 | ត្រីផ្ទក់ 1/ 2/ 3/ | 1.432 | 092 | ស្រាកឺឡាកាស | 0.206 | 168 | ចបកាប់ (ចិន) | 0.004 |
| 017 | ត្រីអណ្ដែង 1/ 2/ 3/ | 0.545 | 093 | ស្រាត្រូវ អេស កា ដេ | 0.181 | 169 | ផ្លែពូថៅ (ខ្មែរ) | 0.002 |
| 018 | ត្រីសមុទ្រ 1/ 2/ 3/ | 0.073 | 094 | ថ្នាំជក់ ( ថ្នាំខ្លាំង) | 0.362 | 170 | ទួណឺវីស (ចិន) | 0.002 |
| 019 | បង្គារ 1/ 2/ 3/ | 0.111 | 095 | បារីនាំចូលម៉ាកហ្វីន | 0.981 | 171 | សាប៊ូបោកខោអាវ ( ថៃ) | 0.139 |
| 020 | ក្ដាម 1/ 2/ 3/ | 0.084 | 096 | ថ្នាំជក់ផ្សេងទៀត | 0.065 | 172 | កូនជ្រុកភ្លើង | 0.015 |
| 021 | ត្រីស្រស់ផ្សេងទៀត 1/ 2/ 3/ | 0.040 | 097 | ក្រណាត់ទេសឯក (លាត)ស | 0.016 | 173 | អំពូលម៉ែត្រ ថៃ | 0.038 |
| 022 | ត្រីឆ្អើ 1/ 2/ 3/ | 0.126 | 098 | ផ្សេងៗ | 0.038 | 174 | ថ្នាំបាញ់សម្លាប់សត្វល្អិត(US) | 0.039 |
| 023 | ប្រហុក | 0.279 | 099 | ក្រម៉ា | 0.010 | 175 | ឈើគូស (វៀតណាម) | 0.012 |
| 024 | ត្រីងៀត 1/ 2/ 3/ | 0.979 | 100 | សារ៉ុង | 0.016 | 176 | អំបោស (ខ្មែរ) | 0.012 |
| 025 | ត្រីខកំប៉ុង 1/ 2/ 3/ | 0.088 | 101 | អាវប្រុសដៃវែង | 0.313 | 177 | ថ្លៃបង់ឱ្យវេជ្ជបណ្ឌិត (ពេទ្យទូទៅ) | 0.626 |
| 026 | បង្គារស្ងួត 1/ 2/ 3/ | 0.094 | 102 | ខោជើងវែង | 0.333 | 178 | ថ្លៃបង់ឱ្យពេទ្យធ្មេញ | 0.199 |
| 027 | ពងមាន់ 1/ 2/ 3/ | 0.070 | 103 | អាវយឺតប្រុស | 0.027 | 179 | ថ្លៃពិគ្រោះជម្ងឺប្រចាំថ្ងៃ | 0.475 |
| 028 | ពងទា 1/ 2/ 3/ | 0.757 | 104 | ស្រោមជើង | 0.023 | 180 | វីតាមីន C | 0.442 |
| 029 | ពងទាប្រៃ 1/ 2/ 3/ | 0.181 | 105 | សម្លៀកបំពាក់ | 0.066 | 181 | ថ្នាំអាស្ពីរីន ៥០០មីលីក្រាម | 0.442 |
| 030 | ទឹកដោះគោកំប៉ុង អាឡាសស្កា 1/2/3/ | 0.638 | 106 | អាវដៃវែងស្រី | 0.290 | 182 | ថ្នាំប៉ារ៉ាសេតាម៉ុល ៥០០មីលីក្រាម | 0.442 |
| 031 | ម្សៅទឹកដោះគោ 1/ 2/ 3/ | 0.222 | 107 | សំពត់ | 0.225 | 183 | ថ្នាំបាក់ទ្រឹមបារាំង ៤៨០មីលីក្រាម | 0.442 |
| 032 | ការ៉េម 1/ 2/ 3/ | 0.119 | 108 | ខោទ្រនាប់ប្រុស | 0.085 | 184 | ថ្នាំស៊ីរ៉ូប្រូបេតាស៊ីន | 0.442 |
| 033 | បន្លែ 1/ 2/ 3/ | 0.174 | 109 | ខោទ្រនាប់ស្ត្រី | 0.112 | 185 | អំពីស៊ីលីន ២៥០ មីលីក្រាមសូវៀត | 0.442 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 034 | ខ្លាញ់ជ្រូក 1/ 2/ 3/ | 0.628 | 110 | ខោជើងវែង/ខោខ្លី | 0.037 | 186 | បង់រុំរបួស | 0.004 |
| 035 | ត្រកួន 1/ 2/ 3/ | 0.353 | 111 | អាវសឺមីស/អាវយឺត | 0.022 | 187 | បង់បិទដំបៅ | 0.004 |
| 036 | ស្លឹកស្ពៃក្តោប 1/ 2/ 3/ | 0.052 | 112 | សម្លៀកបំពាក់ | 0.023 | 188 | វ៉ែនតា (ពង្រីក) | 0.075 |
| 037 | សាឡាត់ 1/ 2/ 3/ | 0.460 | 113 | អាវស្ត្រី/អាវមានក/អាវយឺត | 0.034 | 189 | ច្រាសបោកខោអាវ | 0.004 |
| 038 | ខ្ទឹមបារាំង 1/ 2/ 3/ | 0.213 | 114 | ខោទឹកនោមកូនក្មេង ថៃ | 0.008 | 190 | កង់ថៃ | 0.285 |
| 039 | ស្ពៃខៀវ 1/ 2/ 3/ | 0.022 | 115 | ស្បែកជើងធ្វើពីស្បែក | 0.228 | 191 | កូនកង់រំអិល | 2.378 |
| 040 | ប៉េងប៉ោះ 1/ 2/ 3/ | 0.199 | 116 | ស្បែកជើងជ័រវីនីល | 0.021 | 192 | ប្រេងសាំង | 1.729 |
| 041 | ឃ្លោក 1/ 2/ 3/ | 0.181 | 117 | ស្បែកជើងផ្ទាត់ | 0.040 | 193 | ប្រេងម៉ាស៊ូត | 0.101 |
| 042 | ត្រសក់ 1/ 2/ 3/ | 0.275 | 118 | ស្បែកជើងធ្វើពីស្បែក | 0.105 | 194 | ប្រេងម៉ាស៊ីន | 0.262 |
| 043 | ម្រះ 1/2/3 | 0.100 | 119 | ស្បែកជើងផ្ទាត់ | 0.049 | 195 | សំបកកង់ (ខ្មែរ) | 0.324 |
| 044 | ននោងជ្រុង 1/2/3 | 0.079 | 120 | ស្បែងជើងផ្ទាត់កូនក្មេង | 0.016 | 196 | ពោះវៀនកង់ទំហំ ៦៥០ | 0.120 |
| 045 | ម្ទេសប្លោក (មិនហិរ) 1/2/3 | 0.046 | 121 | អាវកាត់ស្ត្រីដៃវែង | 0.017 | 197 | ថ្លៃឈ្នួលស៊ីក្លូ | 0.455 |
| 046 | ត្រប់ 1/ 2/ 3/ | 0.040 | 122 | អាវកាត់បុរសដៃវែង | 0.007 | 198 | ថ្លៃឈ្នួលម៉ូតូឌុប | 0.453 |
| 047 | ខ្ទឹមបារាំង 1/ 2/ 3/ | 0.083 | 123 | អំបោះដេរខោអាវ | 0.006 | 199 | ថ្លៃឈ្នួលរថយន្តក្រុង | 0.094 |
| 048 | ផ្កាខាត់ណា 1/ 2/ 3/ | 0.141 | 124 | ម្ជុលដេរប៉ាក់ដោយដៃ | 0.026 | 200 | តែមប្រៃសណីយ៍ | 0.057 |
| 049 | បន្លែផ្សេងទៀត 1/ 2/ 3/ | 0.045 | 125 | តម្លៃឈ្នួលស្នាក់នៅជាមួយម្ចាស់ផ្ទះ | 26.983 | 201 | តែមប្រៃសណីយ៍ | 0.405 |
| 050 | ត្រាវ 1/ 2/ 3/ | 0.091 | 126 | តម្លៃឈ្នួលផ្ទះនៅតែឯង | 0.347 | 202 | ទូរទស្សន៍ ជប៉ុន | 0.460 |
| 051 | ដំឡូងវ្ហា 1/ 2/ 3/ | 0.149 | 127 | ដែកគោល | 0.035 | 203 | ក្បាលវីដេអូ | 0.128 |
| 052 | ដំឡូង 1/ 2/ 3/ | 0.116 | 128 | ឈើអារសម្រាប់សាងសង់ | 0.035 | 204 | កូនវិទ្យុ (ចិន) | 0.070 |
| 053 | សណ្តែកបណ្តុះ 1/ 2/ 3/ | 0.049 | 129 | សង្កសី | 0.035 | 205 | ថ្លៃជួលក្បាលចាក់កាសែ្សតវីដេអូ | 0.079 |
| 054 | សណ្តែកកួរ 1/2/3 | 0.138 | 130 | ក្តារបន្ទះ | 0.035 | 206 | លាងហ្វីល/ផ្តិតរូបថត | 0.128 |
| 055 | សណ្តែកបារាំង 1/2/3 | 0.149 | 131 | ស៊ីម៉ង់ត៍ | 0.066 | 207 | កូនកង់សម្រាប់ក្មេង (ថៃ) | 0.056 |
| 056 | សណ្តែកខៀវ 1/2/3 | 0.044 | 132 | ថ្មទំហំ ១ គុណ ២ របស់ខ្មែរ | 0.066 | 208 | កាសែ្សតវីដេអូ C ៦០ | 0.008 |
| 057 | ជ្រក់ត្រសក់ 1/ 2/ 3/ | 0.392 | 133 | ខ្សាច់គ្រើមសម្រាប់បូក | 0.066 | 209 | ថ្នាក់ភាសាអង់គ្លេស | 2.882 |
| 058 | ចេក 1/ 2/ 3/ | 0.633 | 134 | បំពង់ជ័រ | 0.074 | 210 | សៀវភៅធំ | 0.722 |
| 059 | ផ្លែក្រូច 1/ 2/ 3/ | 0.604 | 135 | ខ្សែភ្លើង | 0.023 | 211 | ខ្មៅដៃ (ចិន) | 1.239 |
| 060 | ផ្លែម្នាស់ 1/ 2/ 3/ | 0.071 | 136 | កុងតាក់ភ្លើង | 0.023 | 212 | ប៊ិច (ថៃ) | 0.024 |
| 061 | ក្រូចឆ្មា 1/ 2/ 3/ | 0.111 | 137 | ថ្នាំលាបឈើ | 0.032 | 213 | ក្រដាស អាកាត់ (ឥណ្ឌូនេស៊ី) | 0.118 |
| 062 | ផ្លែល្ហុង 1/ 2/ 3/ | 0.077 | 138 | សាំងក្រអូប | 0.032 | 214 | កាសែតរស្មីកម្ពុជា | 0.333 |
| 063 | ផ្លែប៉ោម (ក្រហ ម1/ 2/ 3/) | 0.117 | 139 | ប្រាក់ឈ្នួលជាងឈើក្នុងមួយថ្ងៃ | 0.051 | 215 | សាប៊ូលុចរ្សប្រើក្នុងបន្ទប់ទឹក (ថៃ) | 0.091 |
| 064 | ផ្លែទំពាំងបាយជូ (ក្រហម 1/ 2/ 3/ | 0.085 | 140 | ថ្លៃទឹក | 1.406 | 216 | សាប៊ូកក់សក់ប៉ាម៉ូលីស | 0.196 |
| 065 | ផ្លែសាវម៉ាវ 1/ 2/ 3/ | 0.182 | 141 | ថ្លៃភ្លើង | 1.843 | 217 | ថ្នាំដុសធ្មេញ Close Up (ថៃ) | 0.172 |
| 066 | ផ្លែធុរេន 1/ 2/ 3/ | 0.279 | 142 | ទៀន | 0.090 | 218 | ច្រាសដុសធ្មេញ | 0.037 |
| 067 | ផ្លែឪឡឹក 1/ 2/ 3/ | 0.172 | 143 | ប្រេងកាត | 0.306 | 219 | ម្សៅភេសសាត់ (ថៃ) | 0.073 |
| 068 | ផ្លែខ្នុរ (ទុំ) 1/ 2/ 3/ | 0.069 | 144 | អុស | 0.936 | 220 | ទឹកអប់ កុងកក (ថៃ) | 0.027 |
| 069 | ផ្លែអំពិល 1/ 2/ 3/ | 0.191 | 145 | ធ្យូង | 0.863 | 221 | ឡាមកោរ | 0.012 |
| 070 | ផ្លែដូង 1/ 2/ 3/ | 0.326 | 146 | សាឡុងឈុតធ្វើពីឈើ | 0.042 | 222 | ទឹកអប់កូឡូញ កម្ពុជា | 0.094 |
| 071 | សណ្តែកដី 1/ 2/ 3/ | 0.130 | 147 | កៅអីឈើ | 0.021 | 223 | អនាម័យ | 0.097 |
| 072 | អំបិតហ្មត់សរ 1/ 2/ 3/ | 0.308 | 148 | គ្រែឈើ | 0.041 | 224 | ថ្លៃធ្វើសក់សម្រាប់ស្ត្រី | 0.108 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 073 | ស្ករត្នោត 1/ 2/ 3/ | 0.281 | 149 | ទូខោអាវ | 0.030 | 225 | កាត់សក់មនុស្សប្រុស | 0.273 |
| 074 | ស្ករស 1/ 2/ 3/ | 0.030 | 150 | កន្ទេលកក់ក្រហម | 0.036 | 226 | កាត់សក់មនុស្សស្រី | 0.069 |
| 075 | អំបិល 1/ 2/ 3/ | 0.082 | 151 | ភួយ | 0.023 | 227 | នាឡិកាដៃ (ជប៉ុន) | 0.933 |
| 076 | ខ្ទឹមស 1/ 2/ 3/ | 0.154 | 152 | មុងនីឡុង | 0.031 | | **សរុប** | **100** |

ប្រភព : វិទ្យាស្ថានស្ថិតិជាតិ និងការគណនារបស់បុគ្គលិក *(ADB)*

សម្គាល់ : C-EF ក្រៅពី 1/; C-EFF ក្រៅពី 1/ និង 2/ និង C-EFFT ក្រៅពី 1/ 2/ 3/

## តារាង១.២ : ប្រទេសកម្ពុជា: រង្វាស់ផ្សេងៗនៃអតិផរណា ខែមករា ឆ្នាំ២០០៣ - ២០០៨

| ខែ | តួលេខរួម | C-EF | C-EFF | C-EFFT | ខែ | តួលេខរួម | C-EF | C-EFF | C-EFFT |
|---|---|---|---|---|---|---|---|---|---|
| មករា 03 | 1.4 | 0.4 | 0.1 | 0.0 | វិច្ឆិការ 05 | 6.7 | 3.4 | 2.4 | 2.0 |
| កុម្ភៈ 03 | 1.8 | 0.5 | 0.2 | 0.1 | ធ្នូ 05 | 6.7 | 3.3 | 2.3 | 1.9 |
| មីនា 03 | 2.1 | 1.1 | 0.5 | 0.3 | មករា 06 | 6.3 | 3.0 | 1.9 | 1.4 |
| មេសា 03 | 1.2 | 0.9 | 0.3 | 0.2 | កុម្ភៈ 06 | 6.2 | 2.8 | 1.7 | 1.2 |
| ឧសភា 03 | 1.9 | 1.0 | 0.6 | 0.4 | មីនា 06 | 5.9 | 2.8 | 1.9 | 1.4 |
| មិថុនា 03 | 1.7 | 1.2 | 0.9 | 0.7 | មេសា 06 | 4.8 | 2.9 | 1.9 | 1.4 |
| កក្កដា 03 | 1.1 | 0.7 | 0.5 | 0.3 | ឧសភា 06 | 4.9 | 3.1 | 2.0 | 1.5 |
| សីហា 03 | 0.8 | 0.9 | 0.6 | 0.1 | មិថុនា 06 | 3.8 | 3.4 | 2.3 | 1.8 |
| កញ្ញា 03 | 0.5 | 0.7 | 0.4 | 0.0 | កក្កដា 06 | 5.1 | 4.0 | 3.0 | 2.4 |
| តុលា 03 | 0.6 | 0.7 | 0.4 | 0.0 | សីហា 06 | 5.1 | 4.1 | 3.3 | 2.6 |
| វិច្ឆិការ 03 | 0.5 | 0.8 | 0.5 | 0.0 | កញ្ញា 06 | 4.4 | 3.9 | 3.2 | 2.6 |
| ធ្នូ 03 | 0.5 | 0.8 | 0.5 | 0.1 | តុលា 06 | 4.1 | 3.4 | 2.9 | 2.5 |
| មករា 04 | 0.6 | 0.8 | 0.5 | 0.1 | វិច្ឆិការ 06 | 3.2 | 3.4 | 2.9 | 2.5 |
| កុម្ភៈ 04 | 0.8 | 0.9 | 0.5 | 0.1 | ធ្នូ 06 | 2.8 | 3.3 | 2.9 | 2.4 |
| មីនា 04 | 0.9 | 0.8 | 0.6 | 0.1 | មករា 07 | 2.6 | 2.8 | 2.8 | 2.4 |
| មេសា 04 | 1.6 | 0.9 | 0.6 | 0.1 | កុម្ភៈ 07 | 2.9 | 2.8 | 2.8 | 2.4 |
| ឧសភា 04 | 2.1 | 1.3 | 0.7 | 0.2 | មីនា 07 | 3.5 | 2.7 | 2.7 | 2.2 |
| មិថុនា 04 | 3.0 | 1.8 | 1.0 | 0.3 | មេសា 07 | 4.0 | 2.7 | 2.9 | 2.4 |
| កក្កដា 04 | 6.0 | 2.5 | 1.8 | 1.2 | ឧសភា 07 | 4.1 | 2.8 | 2.8 | 2.3 |
| សីហា 04 | 6.7 | 2.7 | 1.8 | 1.1 | មិថុនា 07 | 5.6 | 2.4 | 2.6 | 2.0 |
| កញ្ញា 04 | 7.4 | 2.8 | 2.0 | 1.2 | កក្កដា 07 | 6.5 | 2.7 | 3.0 | 2.5 |
| តុលា 04 | 6.0 | 3.2 | 2.3 | 1.3 | សីហា 07 | 5.2 | 1.6 | 1.9 | 1.5 |
| វិច្ឆិការ 04 | 5.8 | 3.2 | 2.3 | 1.3 | កញ្ញា 07 | 6.4 | 1.4 | 1.7 | 1.5 |
| ធ្នូ 04 | 5.6 | 3.3 | 2.4 | 1.4 | តុលា 07 | 8.7 | 2.2 | 2.2 | 1.7 |
| មករា 05 | 5.8 | 3.5 | 2.8 | 1.8 | វិច្ឆិការ 07 | 9.5 | 3.2 | 2.8 | 1.7 |
| កុម្ភៈ 05 | 5.6 | 3.8 | 3.2 | 2.3 | ធ្នូ 07 | 10.8 | 3.8 | 3.2 | 1.9 |
| មីនា 05 | 5.4 | 3.7 | 3.1 | 2.3 | មករា 08 | 13.7 | 6.8 | 5.8 | 4.8 |
| មេសា 05 | 5.9 | 3.8 | 3.0 | 2.3 | កុម្ភៈ 08 | 15.5 | 7.3 | 6.2 | 5.1 |
| ឧសភា 05 | 6.3 | 3.7 | 3.1 | 2.3 | មីនា 08 | 20.3 | 8.5 | 7.0 | 5.7 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| មិថុនា 05 | 7.0 | 3.7 | 2.9 | 2.3 | មេសា 08 | 24.2 | 8.7 | 7.2 | 5.8 |
| កក្កដា 05 | 4.1 | 3.1 | 2.2 | 1.5 | ឧសភា 08 | 25.7 | 9.3 | 7.6 | 6.1 |
| សីហា 05 | 4.5 | 3.3 | 2.3 | 1.6 | មិថុនា 08 | 25.1 | 10.3 | 7.8 | 6.4 |
| កញ្ញា 05 | 5.0 | 3.6 | 2.5 | 1.7 | កក្កដា 08 | 22.3 | 9.4 | 6.9 | 5.5 |
| តុលា 05 | 6.4 | 3.5 | 2.4 | 1.9 | | | | | |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់បុគ្គលិក *(ADB)* ។

កំណត់សម្គាល់: C-EF = Core inflation excluding food អតិផរណានៃទំនិញចាំបាច់មិនរាប់បញ្ចូលមុខម្ហូបអាហារ

C-EFF = Core inflation excluding food and fuel អតិផរណានៃទំនិញចាំបាច់មិនរាប់បញ្ចូលមុខម្ហូបអាហារ និងប្រេងសាំង

C-EFFT = Core inflation excluding food and fuel and transport អតិផរណានៃទំនិញចាំបាច់មិនរាប់បញ្ចូលមុខម្ហូបអាហារ ប្រេងសាំង និងការដឹកជញ្ជូន